# បុណ្យឈាបនកិច្ច ឬ បុណ្យខ្មោច

- រៀបរៀងដោយ : ព្រះគ្រូចៅអធិការ

វត្តត្រពាំងធំ ឃុំពោធិអង្គ្រង ស្រុកគងពិសី
ខេត្តកំពង់ស្ពឺ

- ពិនិត្យកែសំរួល រចនា : ដោយបណ្ណាគារត្រៃរតន៍

- សំរាប់ជំនួយដល់ : ធម្មកថិកថ្មី អាចារ្យ យោគី
និងអ្នកអានសិក្សាស្រាវជ្រាវទាំងឡាយ ។

ព.ស ២៥១៤ គ.ស ១៩៧០

ផ្សាយចេញពី

# www.haotrai.com

ចែកជាឃម្ពូឈានដោយ

MEKONGNET
CONNECTING YOU ALL

AnAnA
Computer
Trusted Service & Quality

# បុណ្យឈាបនកិច្ច ឬ បុណ្យខ្មោច

រៀបរៀងដោយ : ព្រះគ្រូចៅអធិការ

វត្តក្រពាំងធំ ឃុំពោធិអង្គ្រង ស្រុកគងពិសី
ខេត្តកំពង់ស្ពឺ

- ពិនិត្យកែសំរួល រចនា : ដោយបណ្ណាគារត្រៃរតន៍

- សំរាប់ជំនួយដល់ : ធម្មកថិកថ្មី អាចារ្យ យោគី
និងអ្នកអានសិក្សាស្រាវជ្រាវទាំងឡាយ ។

ព.ស ២៥១៤ គ.ស ១៩៧០

# អារម្ភកថា

* * *

នៅក្នុងលោកយើងនេះ ជាតិសាសន៍ណាក៏ដោយសុទ្ធតែមានជំនឿទំនៀមទំលាប់ ប្រពៃណីប្រចាំជាតិសាសន៍រៀងៗ ខ្លួន ។

ដូច្នេះការស្រាវជ្រាវរាវរកប្រភពកំណើតជំនឿទំនៀមទំលាប់ ប្រពៃណីប្រចាំជាតិសាសន៍មួយៗ គឺជាការលំបាកស្មុគ្រស្មាញមួយ ។ កន្លងមកខ្លួនខ្ញុំជាអ្នកទេសនា និងជាអ្នកបង្រៀនធម្មវិន័យមួយរូប ជួបការលំបាកយ៉ាងច្រើនលើការស្វែងរកប្រភពកំណើតនីមួយ ៗ ។ ដោយហេតុនេះហើយ ទើបខ្ញុំលះបង់ពេលវេលាស្រាវជ្រាវចងក្រងអំពី "បុណ្យឈាបនកិច្ច ឬ បុណ្យខ្មោច" ដើម្បីសំរួលដល់អ្នកចិកថ្មី និងលោកអាចារ្យយោគី ( អាចារ្យខ្មោច ) ។

តាមការកត់សំគាល់របស់ខ្ញុំ លោកអាចារ្យយោគីខ្លះក្នុងពិធីនីមួយៗ នៃបុណ្យឈាបនកិច្ច គាត់បានចាត់ចែងធ្វើសព្វគ្រប់ ប៉ុន្តែមិនបានស្វែងយល់ពីអត្ថន័យ និងប្រភពកំណើតបានច្បាស់លាស់ឡើយ ។

ជាអវសានខ្ញុំសូមអធ្យាស្រ័យអំពីអស់លោក អ្នកបណ្ឌិតវិញ្ញូជនទាំងឡាយ លើចំណុចខ្វះខាតខុសឆ្គងនឹងសូមមេត្តាជួយកែសំរួលឱ្យទានផង ដោយអនុគ្រោះ ។ នេះគឺជាបំណងល្អរបស់ខ្ញុំ ។

**សាន់_ហាឡូ**

ព.ស ២៥១៤ គ.ស ១៩៧០

# មាតិកាធម៌

ទំព័រ


- គណៈកម្មការរៀបចំផ្សាយ ........................................
- អារម្ភកថា ........................................................
- បុណ្យឈាបនកិច្ច រឺបុណ្យខ្មោច .................................... ០១
- មរណៈកថា ......................................................... ១៦
- គួររៀបចំខ្លួនប្រតិបត្តិតាមវិន័យ ..................................២៨
- អានិសង្សបុណ្យខ្មោច ............................................ ៣១
- រឿងព្រះចូឡបន្ថកត្ថេរ ............................................. ៣៥
- ប្រវត្តិឆាកបង្សុកូល ................................................ ៣៩
- ប្រវត្តិទង់ក្រពើ - ទង់ព្រលឹង ......................................... ៤៤
- ប្រវត្តិទាក់ទងនឹងមនុស្សស្លាប់ថ្មីៗ ................................. ៥០
- ប្រវត្តិទាក់ទងនឹងទំនៀមទំលាប់ដាក់ខ្មោចបែរក្បាលទៅទិសខាងលិច ៥៤
- ប្រវត្តិទាក់ទងនឹងទំនៀមទំលាប់ដាក់ប្រាក់កាក់ក្នុងមាត់បុគ្គលស្លាប់ ៥៥
- ប្រវត្តិទាក់ទងនឹងទំនៀមដាក់ផ្កា និងទៀនធូបក្នុងដៃបុគ្គលស្លាប់ ៥៧
- ប្រវត្តិទាក់ទងនឹងលោកអភិធម្ម និងលោកមាតិកានៅពេលដង្ហែសព ៥៨
- ប្រវត្តិទាក់ទងនឹងទៀនកាលនៅពេលមានមនុស្សស្លាប់ .............. ៦០


※ ※ ※

# បុណ្យឈាបនកិច្ច រឺ បុណ្យខ្មោច

**នមោតស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

ខ្ញុំព្រះករុណា សូមនមស្ការ ចំពោះព្រះភគវន្តមុនី អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះសទ្ធម្ម និងព្រះអរិយសង្ឃដោយគោរព ។

**សាទរំ សាទរំ ហន្ទ វិហិតា វិហិតា មយា វន្ទនា វន្ទនា មាន ភាជនេ រតនត្តយេ ៕**

កិរិយាថ្វាយបង្គំឯណា ដែលខ្ញុំព្រះករុណាបានធ្វើ ហើយប្រកបដោយសេចក្តីគោរព ក្នុងប្រជុំបីនៃរតនៈ មានព្រះពុទ្ធជាដើមដែលជាភាជន៍គួរតែបុគ្គលថ្វាយបង្គំបូជា ដោយទ្វារទាំងបី មានកាយទ្វារជាដើម កិរិយាថ្វាយបង្គំនោះឯង ជាអំពើដ៏វិសេស ព្រោះញុំាងសម្បត្តិជាលោកិយនិងលោកុត្តរៈ អោយសំរេចបាន។ សូមញុំាងសេចក្តីក្រវល់ក្រវាយ ដែលប្រព្រឹត្តទៅក្នុងកាយ និងចិត្ត នៃ ( ពុទ្ធសាសនិកជនទាំងឡាយ ) អោយវិនាសបាត់បង់ទៅ ។

**តទនន្តរំ ធម្មំ ទេសិស្សាមិ** : បន្ទាប់ពីបទនមស្ការនេះទៅ សូមសំដែងពី " **បុណ្យឈាបនកិច្ច រឺ បុណ្យខ្មោច** " តាមទំនៀមទំលាប់ ប្រពៃណីដែលបានធ្វើរៀងៗមក ដែលមាន

សេចក្តីដូចតទៅ :

នៅក្នុងគ្រួសារខ្មែរ ក៏ដូចជាគ្រួសារជាតិសាសន៍ដទៃទៀត កាលបើមានមនុស្សស្លាប់ គេតែងតែរៀបចំធ្វើបុណ្យជូនដំណើរខ្មោចនោះតាមទំនៀមទំលាប់ ដែលប្រែប្រួលទៅតាមសម័យកាល និងប្លែកគ្នាខ្លះតាមតំបន់នីមួយៗ ។

ខ្មែរយើងចាត់ទុកបុណ្យខ្មោច រឺបូជាសព ជាករណីកិច្ចដែលគ្រួសារសពត្រូវបំពេញ ។ កាលណាគេរំលងប្រពៃណីដោយទុកឳពុក ម្តាយ ជីដូនជីតា បងប្អូនស្លាប់ដូចសត្វតិរច្ឆាននោះនឹងត្រូវទទួលការរិះគន់ពីសង្គម ហើយនឹងមានការស្តាយក្រោយជាពុំខាន ។

ការស្លាប់មានច្រើនបែបយ៉ាងណាស់ ដូចស្លាប់ដោយលង់ទឹក ចងក រន្ទះបាញ់ គ្រោះថ្នាក់ផ្សេងៗជាដើម ។ មនុស្សដែលស្លាប់បែបនេះគេហៅថា " **ខ្មោចតាយហោង** " គឺស្លាប់មិនតាមកាលដែលគេពុំអាចប្រុងប្រៀបទុកជាមុនបាន ។ តាមទំនៀមគេពុំយកខ្មោចតាយហោងទៅបូជាទេ គេយកទៅកប់សិន ចាំបានពេលល្អ ទើបគាស់យកឆ្អឹងមកធ្វើបុណ្យវិញ ។ ប៉ុន្តែសព្វថ្ងៃនេះ គេពុំសូវយកទៅកប់ទេ ដោយខ្វះដីកប់ផង ហើយដោយទំនៀមទំលាប់ប្រែប្រួលផង គេក៏យកខ្មោចប្រភេទនេះមករៀបចំធ្វើបុណ្យបូជាដែរ ។ ឯមនុស្សស្លាប់តាមកាលដូចជាស្លាប់

ដោយមានជំងឺមើលពុំជា រឺស្លាប់ដោយចាស់ជរា ( ទុំជ្រុះ ) គេអាចប្រុងប្រៀបរៀបចំជាមុន បានដូចមានសេចក្ដីអធិប្បាយតទៅ :

~ **មុនពេលស្លាប់** : នៅពេលជិតស្លាប់ គេនិមិន្តព្រះសង្ឃ ៥ អង្គ រឺ ១ អង្គ ក៏បានមកសូត្រធម៌អោយអ្នកជំងឺស្ដាប់ ។ គេត្រូវរក អាចារ្យម្នាក់ទៅជួយមើលខុសត្រូវដល់ដង្ហើមចុងក្រោយ ។

នៅពេលនោះដែរ មិត្តសំលាញ់ក្ដី បងប្អូនកូនចៅក្ដី ដែលបានប្រព្រឹត្តមិនគប្បីចំពោះអ្នកនោះ ត្រូវមកសុំខមាទោស។ បន្ទាប់មកគេអោយអ្នកជំងឺទន្ទេញធម៌ថា " **ពុទ្ធោអរហំ** " ហើយអោយតាំងស្មារតីអោយនឹងក្នុងអំពើល្អ ដែលខ្លួនបានធ្វើ ហើយកុំអោយខ្វល់ខ្វាយជំពាក់ចិត្តទៅលើគ្រួសារ លើទ្រព្យសម្បត្តិជាដើម ។

នៅខណៈនោះគេនាំគ្នារៀបចំគ្រឿងប្រដាប់បន្ទុង មានគ្រឿងបរិភោគ ឧបភោគ និងរបស់ផ្សេងៗសំរាប់ប្រគេនព្រះសង្ឃនៅពេលស្លាប់ទៅ ។ ប្រដាប់ប្រដាទាំងនោះ ត្រូវយកទៅបង្ហាញអ្នកជំងឺអោយបានឃើញ ហើយត្រេកអរនឹងកុសលផលបុណ្យនោះផង ។ ចំណែកលោកអាចារ្យក៏រៀបចំលញ់ **ទៀនកល្ប ទៀនគោល** ធ្វើ **ស្លាត្រួយ ឆន់ព្រលឹង** និង **សុពារ**

**ធាតុ ៦ សង្ខិត** ( ជាបន្ទះធ្វើដោយមាស រឺប្រាក់ រឺទង្ហា រឺស្លឹករឹត រឺក្រដាសក៏បានទុកដាក់ដល់ពេលស្លាប់នៅត្រង់ថ្ពាស ក្បាលបបូរមាត់ លើចង្កាក្នុងដៃ ប្រណម្យ និងលើដើមទ្រូង )។ គេអុចទៀនកល្ប នៅពេលជិតដាច់ខ្យល់ និងនៅពេលស្លាប់ ។ ឯស្លាត្រួយគឺស្រទាប់ស្លឹកចេក ដែលគេដោតស្លា ម្លូ ធូប ហើយ ដែលធ្វើទុកសំរាប់អោយអ្នកជំងឺកាន់ថ្វាយដល់ **ព្រះចូឡាមណី** ចេតិយនៅស្ថានត្រៃត្រឹង្ស ដែលញុះព្រះកេសា និង ស្មៀតព្រះកេសរបស់ព្រះពុទ្ធ នៅពេលដែលកំលាំងកាន់តែខ្សោយទៅ ។ គេធ្វើទង់ព្រលឹងដោយសំពត់ស ប្រវែងប្រហែល ១ ហត្ថ នៃអ្នកជំងឺ ។ នៅលើទង់ព្រលឹងនោះជួនកាល គេទុកទំនេរ ជួនកាលគេចារគាថា ជួនកាលទៀតគេគូររូប ព្រះចូឡាមណី ។ នៅតាមតំបន់ខ្លះ គេគូររូបក្រពើតំណាងក្រុងពាលី ។ គេដាក់ទង់ក្រពើនោះនៅក្បាលគ្រែអ្នកជិតស្លាប់ ហើយបន្ត អំពោះពីទង់ព្រលឹងទៅដល់រូបព្រះពុទ្ធ រឺព្រះចូឡាមណី ។ គេមានជំនឿថា លុះអ្នកនោះស្លាប់ទៅ ទង់ព្រលឹងនេះឯង នឹងទ្រព្រលឹង រហូតដល់ពេលចាប់ភពថ្មី ។ នៅជុំវិញ និងនៅខាងលើអ្នកជំងឺ គេចងសំពត់ស រឺព្រះបដាតីបដាដែលគេគូរជីវប្រវត្តព្រះពុទ្ធ ។

-**ក្រោយពេលស្លាប់** : លុះមនុស្សនោះផុតដង្ហើមទៅ ហើយអាចារ្យចូលទៅបិទភ្នែក និងមាត់ខ្មោច ហើយយកសុពារ

បាតទាំង ៦ សន្ធឹកមកដាក់តាមកន្លែងដែលត្រូវដាក់ ។ រំពេច នោះគេយកទៀនកល្បមកអុជបិទនៅក្បាលគ្រែ ហើយយកទៀន គោល ៥ ទៀតមកអុជបិទស្បែរក្បាល ស្មា និងជើងរបស់ខ្មោច។

ឯទៀនកល្ប ដែលគេបានអុជ តាំងពីពេលជិតស្លាប់នោះ ត្រូវអុជបន្តទៅកូនចង្កៀងប្រេងកាត់ជំនួសវិញ ។ បន្ទាប់មកគេ រៀប **ចង្កៀនត្បូង** ដែលមានស្រូវពន្លៃ ១ ល្អី ប្រាក់ ១ បាត សំពត់ ស ៥ ហត្ថ ចេកទុំ ១ ស្និត និងចង្កៀងប្រេងកាតនោះ ដាក់ តំកល់នៅចុងជើងខ្មោច ។ នៅក្រោមកន្លែងតំកល់ទៀនត្បូង នោះ គេដាក់ថ្ម ១ ដុំ និងទឹក ១ ក្អម ។ តាមជំនឿគេថា ការអុជ បន្តភ្លើងទៀនកល្បមកចង្កៀងប្រេងកាត ជានិមិត្តរូប នៃជីវិត ដែលរលត់ ពីរូបមួយទៅបន្តក្នុងរូបថ្មីទៀត ។ តាមទំនៀម ទំលាប់នៅតំបន់ខ្លះ គេយកដីអាចំបំណះមួយដុំដាក់ក្នុងល្អីស្រូវ ពន្លៃ ជាការសំគាល់ថា រូបកាយនឹងត្រូវក្លាយទៅជាដីវិញ ហើយ ក្នុងពេលដ៏ឆាប់នឹងផ្សំផ្គុំកើតបានជារូបកាយមនុស្សជាថ្មី ។ នៅ មុខផ្ទះខ្មោច គេដាក់ **ឆន់ក្រពើ** មួយ រឺមួយគូជាសញ្ញាអោយដឹង ថា នៅផ្ទះនោះមានមនុស្សស្លាប់ថ្មីៗ ។

មុននឹងដាក់ខ្មោចទៅក្នុងមឈូស តាមទំនៀមទំលាប់ គេ ត្រូវលើកខ្មោចនោះចំអាសទឹកសិន ហើយលាបទឹកអប់សិតសក់ ( សិតទៅក្រោយ ៣ ដង រួចសិតមកមុខ ៣ ដង ដើម្បីជាប្រស្នា

ថា ការវិលកើតស្លាប់ ត្រលប់ចុះឡើងក្នុងភព ៣ ) ។ បន្ទាប់មក គេយកសំពត់ស ៤ ហត្ថ ស្លៀតអោយខ្មោចដាក់ថ្នក់មកខាងមុខ សំពត់ស ៤ ហត្ថ ទៀតស្លៀកដាក់ថ្នក់ទៅក្រោយវិញ ដើម្បីជា ប្រស្នាថាមានអវិជ្ជាបិទមុខ បិទក្រោយ និងតណ្ហាចាក់ស្រែះគ្នា។ សំពត់ ៤ ហត្ថទៀតពានា ពាក់ពីលើស្មាខាងស្តាំ ។ រួចហើយគេ យកខ្សែបាសចងខ្មោចត្រង់ក កដៃ និង កជើង ។ ការចងខ្មោច បែបនេះ មានទំនាក់ទំនងទៅនឹងផ្លូវធម៌ថា : មនុស្សយើងមាន ចំណងលោកិយ ៣ ប្រការគឺ: ប្រពន្ធ រឺប្តី កូន នឹងទ្រព្យសម្បត្តិ។ បើអ្នកណាផុតពីចំណងនេះបាន នឹងរួចផុតសង្សារវដ្ត ។ តមក ទៀតគេយកមាស រឺ ប្រាក់មួយកាក់ទៅបង់ក្នុងមាត់ខ្មោច ដើម្បី ជាគ្រឿងពិចារណាថា នៅពេលស្លាប់ គេពុំអាចយកទ្រព្យ សម្បត្តិទៅផងបានទេ ទោះបីប្រាក់មួយកាក់ក្នុងមាត់នេះ ក៏យក ទៅពុំបានដែរ ។ នៅទីបញ្ចប់គេយកសំពត់ស ប្រវែង ១ ចំអាម ៤ ជ្រុង គ្របមុខអោយខ្មោចរួចលើកខ្មោចដាក់លើស្នប ( សំពត់ រុំខ្មោច ១២ ហត្ថ ) ។ លុះរុំខ្មោចរួចហើយ គេចងខ្សែបាសម្តង ទៀត ទើបលើកដាក់ទៅក្នុងក្តារមឈូស ។ ខណៈនោះគេនិមន្ត ព្រះសង្ឃបង្សុកូល ។

ចំពោះគ្រួសារក្រខ្សត់ ពិធីបូជាសពអាចប្រព្រឹត្តទៅនៅ ថ្ងៃនោះ ។ ចំពោះគ្រួសារអ្នកមានគ្រាន់បើ អាចតំកល់សពនោះ

ទុកក្នុងរវាងពីរ បីថ្ងៃទៀត ។ ចំណែកសពស្ដេច រឺព្រះសង្ឃចៅអធិការវត្ត គេដំកល់ដាក់ក្នុងកោដ្ឋទុកយូរថ្ងៃទើបបូជា ។

-**ក្បួនដង្ហែ** និង **ពិធីរំលាយសព** : លុះថ្ងៃឈាបនកិច្ចមកដល់ គេត្រូវរៀបក្បួនដង្ហែសពនោះឆ្ពោះទៅកាន់ឈាបនដ្ឋាន ។ មុនរំកិលសពចេញពីទីតំកល់ គេនិមន្តព្រះសង្ឃបង្សុកូលជូនកាលគេព្រារព្ធពិធីបង្វិលពពិល ៣ជុំ ជុំវិញមឈូស បន្ទាប់មកទៀតតាមទំនៀមទំលាប់ នៅពេលរំកិលសពចេញទៅអាចារ្យយោគីយកក្អមទឹកស្រោចរំងាប់ដុំថ្ម រួចទាត់ទំលាក់ចោលទៅជីន្ទូវក្អមទឹក និងដុំថ្មនោះ ( ប្រហែលមានន័យធ្វើរបអោយបែកឆ្ងាយទៅ ) ។

ឯក្បួនដង្ហែសពមានរបៀបដូចតទៅនេះ :

- ព្រះសង្ឃ ១ អង្គ អភិធម្ម គង់លើគ្រែស្នែងភាវនាធម៌អភិធម្ម ។

- ព្រះសង្ឃ ៤ អង្គ មាតិកា គង់លើអាសនៈមួយដ៏សមគួរ ដែលមិនឆ្ងាយពីមឈូសដាក់សព សូត្រធម៌ មាតិកាសត្តប្បករណាភិធម្មវែង ឬខ្លីស្របតាមពេលវេលា ។

- អាចារ្យយោគីកាន់ទង់ព្រលឹង

- វង់ភ្លេងខ្មោច ( ខ្លងខែក )

- អ្នកព្រោយលាជ ក្មេងស្រីស្លៀកពាក់ស ជាកូន រឺសាច់

ញាតិរបស់សព ចាចលាជទៅស្តាំម្តង ឆ្វេងម្តង ដោយទន្ទេញធម៌បណ្តើរផង ហើយមើលទៅមុខជានិច្ច ។ គ្រាប់លាជដែលចាចទៅដីជាតំណាងឆ្អឹង នៃខ្មោចដែលនៅរាយប៉ាយលើដី ។

- អ្នកបួសមុខភ្លើង ( ក្មេងប្រុសជាកូន រឺសាច់ញាតិរបស់សពគោរសក់ ស្លៀកស ពាក់ស ) ។ នៅជុំវិញក្បាលមានខ្សែស្សរភ្វាំងចងបន្តពីមឈូសមក ។ គេថាខ្សែស្សរភ្វាំងនោះជានិមិត្តរូប នៃឆាកជីវិត ដែលបន្តគ្នាដូចច្រវ៉ាក់ ហើយការបួសមុខភ្លើងនេះគឺជាកិច្ចតបស្នងសងគុណមួយដែរ ។

- អ្នកភ្លុក ( អ្នកដុតខ្មោច ) ៤ នាក់ សែងមឈូសយកជើងទៅមុខ ។ សព្វថ្ងៃនៅទីក្រុង គេនិយមដាក់មឈូសហែលើរថយន្ត ។ អ្នកទូលទៀនស្បូង ( ក្មេង រឺអ្នកដែលពេញចិត្តរបស់សព ) ។

- គ្រួសារ និង ញាតិមិត្តរបស់សព ។

លុះដល់ទីប៉ាឆាហើយ គេហែប្រទក្សិណ ៣ជុំ ជាឧត្តរាពត៌ ( ពីខាងឆ្វេងនៃប៉ាឆា ) រួចហើយដាក់មឈូសលើជើងថ្ករយកក្បាល ទៅទិលខាងលិច ។ គេបើកគំរបមឈូសឡើងអាចារ្យក៏បើកស្នប បើកកន្សែងគ្របមុខ ( កូនចៅខ្លះយកកន្សែងនេះទុកដោយមាន ជំនឿថា នាំអោយមានសិរីសួស្តីរកស៊ីមានបាន ) រួចកាត់ចំណងខ្សែបាសហើយនិមន្តលោកបង្សុកូល។

បន្ទាប់មកទើបញាតិមិត្តនាំគ្នា យកផ្កា ទៀនធូបទៅដាក់លើសព សុំខមាទោសជាចុងក្រោយ ។ រួចហើយអាចារ្យយោគី និងអ្នកភ្លុក ៤ នាក់ អុជចន្លុះមួយដើមម្នាក់ ដើរព័ទ្ធជុំវិញមឈូស ៣ ជុំ ជាឧត្តរាពត៌ ហើយអាចារ្យក៏ដុតភ្លើងបូជាសពនោះទៅ ( ចំពោះជនជាសាមញ្ញ ) ។

ចំពោះសពមន្ត្រីរាជការ ព្រះសង្ឃមានបណ្ដាស័ក្តិ គេនិយមសូត្រសុន្ទរកថា ថ្លែងពីជីវប្រវត្តសព និងវិយោគទុក្ខ នៃញាតិមិត្តមុនពេលបូជា ។ ចំពោះអ្នកបូជាដែលហៅថាថ្វាយ ឬប្រទានភ្លើងនោះ គេនិយមយកអ្នកមុខការណាម្នាក់ ដើម្បីថ្វាយប្រទានភ្លើងតាមការពេញចិត្តរបស់សាមីសព ។

នៅពេលដែលភ្លើងកំពុងឆេះសព គេនិមន្តលោកបំបួសមុខភ្លើង ហើយទេសនាមុខភ្លើងទៀត ។ គេអាចផ្សឹកអ្នកបួសមុខភ្លើងនៅពេលបូជាសពរួច ជូនកាលគេទុករហូតដល់ព្រឹកស្អែកទើបដាក់ផ្នួសក៏បានដែរ ។

លុះ ២ រឺ ៣ ម៉ោង ក្រោយមក រូបនៃសាកសពក៏ឆេះសុះអស់ ។ អ្នកភ្លុកយកសំពត់គ្របមឈូស ចោលរំលងភ្លើង ៣ ដង ដើម្បីរំងាប់ចង្រៃឧបទ្រព ។ យោគីយកទឹកមន្ត ( ទឹកសំបូរមាស ) មួយផ្តិលអ្នកភ្លុកកាន់ក្ពមទឹកម្នាក់មួយ ដើរប្រទក្សិណជាឧត្តរាពត៌ ៣ ជុំ ហើយរលត់ភ្លើង ។ បន្ទាប់មកគេបាចគ្រាប់ស្រូវ

សណ្តែក ល្ង នៅលើគំនរឍ្យូង និងផេះ ដើម្បីព្រោះពិធីប្រែរូប។ ឯគ្រាប់ធញ្ញជាតិដែលចាចនោះ ជានិមិត្តរូប នៃការស្លាប់ ដែលជាសំណាបនៃជីវិតថ្មី ។

ពិធីប្រែរូបប្រព្រឹត្តទៅ ៣ ដង ( ដើម្បីអោយពិចារណាទៅតាមភពទាំង ៣ ) ។ ដំបូងយោគីយកចប ប្រមូលធ្យូងធ្វើជារូបមនុស្សមានក្បាលទៅខាងកើតវិញ ហើយសួរថាល្អរឺទេ ? អ្នកភ្ញុកឆ្លើយថា មិនល្អទេ ក៏ធ្វើរូបមនុស្សម្តងទៀត មានក្បាលទៅខាងលិចហើយសួរដូចមុនទៀត ។ គេឆ្លើយថា នៅមិនទាន់ល្អទេ ។ អាចារ្យធ្វើរូបមនុស្សមានក្បាលទៅទិសខាងកើតវិញរួចសួរបញ្ជាក់ថា ល្អហើយរឺនៅ ? គេឆ្លើយថា ល្អហើយ ! ទើបយកស្លឹកចេក មួយផាងគ្របលើរូបនេះ ហើយយកសំពត់ស ៥ ហត្ថមកដាក់លើស្លឹកចេក ។

នៅទីបញ្ចប់ គេនិមន្តលោកបង្សុកូល រឺគេអោយយោគីបង្សុកូលទាកយកសំពត់សនោះទៅ ។ លំដាប់នោះទើបគ្រួសារសពនាំគ្នារើសអដ្ឋិធាតុ យកមកលាងទឹកម្ពរ ទឹកសំបូរមាស និងទឹកដូងខ្ចី ។ នៅពេលរើសធាតុ កូនចៅណារើសបានប្រាក់កាក់ ឬ ធ្មេញរបស់សព គេចាត់ទុកប្រាក់ រឺធ្មេញនោះជាអំណោយពិសេសរបស់សព ដល់កូនចៅនោះ ហើយត្រូវថែរក្សាអោយបានគង់វង់ ។ ឯអដ្ឋិធាតុ ដែលលាងស្អាតហើយគេយកទៅដាក់

កោដ្ឋតូចមួយ ដែលគេយកទៅតាំងនៅក្នុងផ្ទះ ។

នៅយប់ថ្ងៃដដែលនេះ គេនិមន្តព្រះសង្ឃ សូត្រមន្ត ទេសនា ហើយព្រឹកស្អែក គេធ្វើចង្ហាន់ប្រគេនព្រះសង្ឃ ជាវថ្ងង ដើម្បីបញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធ នៃសព ។ លុះដល់គំរប់ ៧ ថ្ងៃ បន្ទាប់មកខួប ១០០ថ្ងៃ ក៏គេប្រារព្ធធ្វើបុណ្យដូចនេះទៀត ។ ក្រោយពីបានធ្វើបុណ្យ ១០០ថ្ងៃ ហើយ គេអាចទុកអដ្ឋិធាតុ នៅក្នុងផ្ទះតទៅទៀតក៏បាន រឺក៏យកទៅបញ្ចុះក្នុងចេតីយ៍នៅវត្តក៏បាន ។ អំណើះតទៅមុខទៀត គេគ្រាន់តែរំលឹកគុណដោយធ្វើបុណ្យឧទ្ទិសកុសលតាមពេលវេលាជាប្រពៃណីតទៅ ។

ចំពោះការកាន់ទុក្ខ គ្រួសារផ្ទាល់នៃសព និយមកោរសក់ ស្លៀកពាក់ ស រឺ ខ្មៅ រឺស្លៀកខ្មៅ ពាក់ ស ។ ជាទូទៅ គេកាន់ទុក្ខចំនួន ១០០ថ្ងៃ ប៉ុន្តែមានអ្នកខ្លះកាន់ទុក្ខរហូតមួយឆ្នាំក៏មាន។

ក្នុងសម័យ **ហ្វូណន** ការកាន់ទុក្ខ គេត្រូវតែកោរសក់ និងកោរពុកមាត់ ។

**វិធីរំលាយសពមាន ៤ យ៉ាងគឺ :**

១. យកសពទៅបោះចោលក្នុងទន្លេ

២. យកសពទៅបូជាដោយភ្លើង

៣. យកសពទៅកប់ចោលក្នុងព្រៃ

៤.យកសពទៅដាក់ចោលក្នុងព្រៃស្មសានអោយសត្វស៊ី។

ក្នុងករណីបូជាដោយភ្លើង គេតែងប្រមូលធាតុដែលនៅសល់យកទៅដាក់ក្នុងកោដ្ឋមួយបិទជិត ហើយយកទៅបោះចោល ក្នុងទឹកទន្លេ ។ បើជាព្រះមហាក្សត្រ កោដ្ឋនោះធ្វើពីមាស បើជានាម៉ឺន សព្វមុខមន្ត្រី គេប្រើកោដ្ឋប្រាក់ ហើយបើជារាស្ត្រសាមញ្ញគេប្រើកោដ្ឋដី ។

**សម័យចេនឡា** : អ្នកដំណើរចិនឈ្មោះ **ម៉ាត្វនលិន** បានសរសេរទុកថា ក្នុងករណីកាន់ទុក្ខ ពួកកូនចៅនៃសព ត្រូវកោរសក់យំស្រែក យ៉ាងខ្លាំង ហើយអត់បាយអស់រយៈពេល ៧ថ្ងៃ ទៀតផង ។ សពត្រូវគេប្រមូល ធាតុដាក់ក្នុងកោដ្ឋធ្វើពីមាស រឺពីប្រាក់ ហើយបោះចោលទៅក្នុងទឹកដ៏ជ្រៅ ។ ពួកអ្នកក្រគេប្រើកោដ្ឋធ្វើពីដី ហើយមានលាបពណ៌ផ្សេងៗ ។ មានអ្នកខ្លះទៀតពេលមានមនុស្សស្លាប់ គ្រាន់តែយកទៅដាក់ចោលក្នុងព្រៃភ្នំ ទុកអោយសត្វស៊ីជាការស្រេច ។

**សម័យអង្គរ** : លោក **ជីវតាក្វាន់** បានកត់សំគាល់ឃើញថា ពេលមានមនុស្សស្លាប់ គេឥតមានដាក់ក្តារមឈូសទេ គេយកតែកន្ទេលក្រាលពីក្រោម យកកំណាត់សំពត់ក្រាលពីលើ ហើយគេយកទៅព្រៃ ។ លុះសែងដល់ក្រៅក្រុង ដល់កន្លែងណាមួយស្ងាត់គេក៏ដាក់ខ្មោចនោះចោល ហើយត្រលប់មកវិញ ដើម្បីទុកអោយសត្វស៊ី ។ ប៉ុន្តែលោក ជីវតាក្វាន់ ក៏បានសង្កេតឃើញ

ថា មានគេយកខ្មោចទៅដុតបូជាខ្លះៗ ហើយ ។ ពេលកាន់ទុក្ខ គេឥតស្លៀកពាក់ ស ទេ គេគ្រាន់តែគោរសក់ ( ប្រុសៗ ) រឺកាត់សក់ ( ស្រីៗ ) ។

**សម័យបច្ចុប្បន្ន** : ខ្មែរយើងសព្វថ្ងៃ ឃើញថា និយមប្រើវិធីបូជាច្រើនជាងគេ ឯខ្មែរនៅកម្ពុជាក្រោម ច្រើននិយមយកសពទៅកប់ អស់មួយរយៈពេល រួចហើយទៅ គេធ្វើបុណ្យ ( លើកសព ) រើសធាតុដាក់ក្នុងកោដ្ឋ យកទៅទុកក្នុងផ្ទះ រឺយកទៅតំកល់ក្នុងចេតិយដែរ ។

**អំពីប្រទីត្តបន្ទុខ :**

មនុស្សជំនាន់ដើមមានជំនឿប្រាកដថា : មនុស្សស្លាប់ទៅមិនសូន្យទេ គឺមានព្រលឹងទៅចាប់ជាតិថ្មីទៀត ។ គេបានបែងចែកព្រលឹងជា ៣ ប្រភេទ គឺ :

- ព្រលឹង ធំ ចេញពីខ្លួនមនុស្ស ៦ ខែ មុនពេលស្លាប់
- ព្រលឹងតូចចេញពីខ្លួនមនុស្សនៅពេលផុតដង្ហើម ស្លាប់
- ព្រលឹងខ្លះទៀត ស្លាប់ ៦ ខែ ហើយទើបព្រមចេញ ។

ដល់កាលណាមនុស្សស្លាប់ទៅគេយកសាកសពទៅកប់ ហើយគេយកគ្រឿងប្រដាប់សំភារៈបរិក្ខាដែលបុគ្គលនោះធ្លាប់ប្រើប្រាស់កាលដែលកំពុងរស់នៅដូចជា : កាំបិត ពូថៅ ចបកាប់ ចបជីក កន្ទេល ឆ្នាំងចាន ជាដើម ទៅកប់ជាមួយដែរ

ដើម្បីទុកអោយប្រើប្រាស់ តទៅទៀត ។

លុះដល់គ្រាក្រោយមក លទ្ធិពុទ្ធសាសនា ត្រូវបាននាំមកក្នុងប្រទេសខ្មែរយើងមានន័យលំនាំគ្នា នឹងជំនឿ ដែលអ្នកស្រុកមានស្រាប់មកហើយផង ពុទ្ធសាសនាមានគោលចារឹកច្បាស់លាស់ទៀតផង ខ្មែរយើងក៏ទទួលយកពុទ្ធសាសនានេះ គោរពប្រតិបត្តិរៀងមក ។

ដោយហេតុនេះហើយ បានជាគ្រប់គ្រួសារខ្មែរទាំងអ្នកមាន ទាំងអ្នកក្រីក្រ រឺជនអនាថាក្តី ពេលមានមនុស្សស្លាប់គេតែងរៀបប្រដាប់បន្ទុង បញ្ជូនទៅអោយអ្នកដែលស្លាប់ទៅ ។

ប្រដាប់បន្ទុង មានគ្រឿងឧបភោគ បរិភោគ មាន អង្ករ អំបិល ប្រហុក ត្រីងៀត ត្រីឆ្អើរ កន្ទេល ខ្នើយ ភួយ មុង ផ្ទាំងបានស្លាបព្រា ចាន់ កែវ កំសៀវ កាំបិត ពូថៅ ឈើច្រត់ ជាដើម ។ ប្រដាប់បន្ទុងនេះមានតិច រឺច្រើន ទៅតាមសទ្ធា រឺធនធានរបស់គ្រួសារសព រឺកូនចៅរបស់សព ។

ការទស់បន្ទុង គេនិយមនិមន្តភិក្ខុជាថេរ ដែលបានទ្រទ្រង់វិបស្សនា កម្មដ្ឋាន មានសីលបរិសុទ្ធ គួរជាទីជ្រះថ្លា ។ តំបន់ខ្លះគេយកប្រដាប់ បន្ទុងនេះ ប្រគេន រឺវេរចំពោះសង្ឃតែម្តងតាមការពេញចិត្ត របស់អ្នកដើមបុណ្យ ។

ការសំដែងមកអំពីបុណ្យ ឈាបនកិច្ច រឺបុណ្យខ្មោច និង

អំពីប្រវិត្តបន្ទុង តាមទំនៀមទំលាប់ ប្រពៃណីខ្មែរ ចប់ដោយសង្ខេបតែប៉ុណ្ណោះ ។ សូមឧទ្ទិសបុញ្ញរាសី គឺគំនរបុណ្យដែលកើតអំពីអាមិសទាន និងធម្មទាន ក្នុងពេលនេះ ជូនដល់ដួងវិញ្ញាណរបស់ ( ឈ្មោះអ្នកស្លាប់ថ្មីៗ ) សូមទទួល អនុមោទនាត្រេកអរ ចំពោះចំណែកបុណ្យនេះ សូមបានទៅសោយសម្បត្តិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។

**ធម៌ទេសនាចប់តែប៉ុណ្ណេះ ឯ វី ! ។**

# មរណកថា

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

តទៅនេះ សូមសំដែងអំពី " **មរណៈ** " ។

**មរណៈ** ប្រែថា ស្លាប់ **មច្ចុ** ប្រែថា ស្លាប់ (សំស្រ្កិតថា: **ម្ឫត្យុ ឬ ម្រិត្យូច**) ។

**មរណៈ** សេចក្តីស្លាប់នេះមានពីរយ៉ាង :

១. **កាលមរណៈ** សេចក្តីស្លាប់តាមកាលកំណត់ ឬដោយអស់អាយុ ។

២. **អកាលមរណៈ** សេចក្តីស្លាប់មិនតាមកាលកំណត់ បានថា មិនទាន់អស់អាយុផងស្លាប់ ( ស្លាប់ពីក្មេង ) ស្លាប់ដោយជម្ងឺ ឬគ្រោះថ្នាក់ផ្សេងៗ ។

**មរណៈ** សេចក្តីស្លាប់នេះ មានឈ្មោះហៅច្រើនយ៉ាងខុសៗគ្នាទៅតាមឋានៈ តួនាទី និងគុណសម្បត្តិ នៃបុគ្គលដែលស្លាប់នោះ ។ ព្រះមហាក្សត្រថា សោយទីវង្គត ព្រះសង្ឃ សុគតលោកអ្នកមានគុណ មានមាតាបិតា ជីដូនជីតា ជាដើម អនិច្ចធម្មឬអនិច្ចកម្ម ។ បើមនុស្សធម្មតា : ស្លាប់ ដោយត្រង់តែម្តង ។ បើសត្វតិរច្ឆាន : ងាប់ ឬតែសាក ។ ប៉ុន្តែបើមនុស្សយើងស្លាប់ដោយគ្រោះថ្នាក់ផ្សេងៗដូចជាលង់ទឹក រន្ទះបាញ់ជាដើម គេប្រែ

ពាក្យថា ខ្មោចតែហោង ព្រោះអ្នកស្លាប់នោះឯងមិនបានដឹងខ្លួន ជាមុនមិនបានទឹកដល់ព្រះធម៌ ឬភាវនាធម៌ ។ តាមជំនឿ ត១ មកថា : ខ្មោចតៃហោងនេះច្រើនមកលង គេឯង បណ្តាលឱ្យ ឃើញនេះឃើញនោះគួរអោយខ្លាច ។

**ស្លាប់គឺអ្វី** ? សំនួរនេះជាប្រធានបទ សំរាប់ធម្ម ទេសនាក្នុងពេលនេះ ។

អាត្មាភាពចង់រស់យូរ ! អាត្មាភាពដឹងថា ញាតិញោម ទាំងអស់គ្នាក៏ចង់រស់យូរ ។ យើងទាំងអស់គ្នា ស្រលាញ់ជីវិត ។ យើងជូនពរគ្នាទៅវិញ ទៅមកអោយបានប្រកបនូវពរ ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ គឺ អោយមានអាយុវែង ពណ៌សម្បុរ ល្អសុខសប្បាយ និងប្រកបដោយកំលាំងបរិបូរណ៍គ្រប់យ៉ាង ។ យើងដឹងដែរថា យើងទាំងអស់គ្នាត្រូវតែស្លាប់ជៀសមិនរួច ដូច លោកអ្នកប្រាជ្ញទស្សនវិទូ បាននិយាយថា " មនុស្ស គឺជាសត្វ ដែលមានសតិសម្បជញ្ញៈ ដឹងខ្លួន ថា ខ្លួនត្រូវតែស្លាប់ " ប៉ុន្តែ យើងអត់ចង់ស្លាប់ទេ ហើយយើងព្រួយចិត្តណាស់ កាលណា យើងទឹកដល់សេចក្តីស្លាប់ ។ យើងខំបំភ្លេចរឿងស្លាប់ យើងខំ លួងលោមខ្លួនយើងថា យើងមិនទាន់ដល់ពេលស្លាប់ទេ យើង នៅមានអាយុវែង ដើម្បីអោយចិត្តយើងរលាស់ចោលនូវសេចក្តី ភ័យតក់ស្លុត ដើម្បីអោយចិត្តយើងសប្បាយរីករាយក្នុងការប្រឹង

ប្រែងប្រកបមុខរបរចិញ្ចឹមជីវិត ។ តើអ្នកណាមួយបានដឹងច្បាស់ថា សេចក្តីស្លាប់នោះមានលក្ខណៈពិតប្រាកដយ៉ាងណា ? ក្នុងចំណោមយើងទាំងអស់គ្នាកំពុងរស់នេះ តើអ្នកណាមួយមានការពិសោធន៍គ្រប់គ្រាន់ក្នុងរឿងស្លាប់ ! ដើម្បីនិយាយប្រាប់គេអោយគេជឿ ? ។ ក្នុងលោកយើងនេះ រាប់តាំងពីអ្នកក្រីក្របំផុតរហូតដល់អ្នកមានបំផុត រាប់តាំងពីទាសាទាសីរហូតដល់ស្តេចអ្នកណាក៏ត្រូវតែស្លាប់ ចៀសមិនផុតដែរ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងថា : **នអន្តលិក្ខេ នសមុទ្ទមជ្ឈេ នបព្វតានំ វិវរំ បវិស្ស ន វិជ្ជតី សោ ជគតិប្បទេសោ យត្ថដ្ឋិតំ នប្បសហេយ្យមច្ចុ ៕**

បុគ្គលទៅឰដ៏អាកាស ក្នុងកណ្តាលសមុទ្រ កាន់ចន្លោះនៃភ្នំ ក៏មិនរួចចាកសេចក្តីស្លាប់បាន ព្រោះប្រទេសលើផែនដីដែលបុគ្គលឋិតនៅហើយ សេចក្តីស្លាប់គ្របសង្កត់មិនបាននោះមិនដែលមានឡើយ ។

**ទហរា ចមហន្តា ច យេពាលា យេច បណ្ឌិតា សព្វេ មច្ចុវសំ យន្តិ សព្វេ មច្ចុបរាយនា ៕**

ទាំងក្មេង ទាំងចាស់ ទាំងពាល ទាំងបណ្ឌិត សុទ្ធតែលុះក្នុងអំណាច នៃសេចក្តីស្លាប់ សុទ្ធតែមានសេចក្តីស្លាប់ជាខាងមុខ ។ នឹកដល់សេចក្តីស្លាប់ មនុស្សភ័យតក់ស្លុតណាស់ ។ ស្លាប់

គឺទៅលែងត្រលប់វិញ លែងបានមកឃើញមុខ ឪពុក ម្តាយ ប្រពន្ធកូន លែងបានមកឃើញ ទ្រព្យសម្បត្តិដែលបានសន្សំកសាង លែងបានឃើញអ្វីៗទាំងអស់ ដែលខ្លួនធ្លាប់ឃើញ ។ ពេលនៅមានជីវិតមនុស្សមានសេចក្តីសង្ឃឹម ។ អ្នកណាក៏ខិតខំកសាងអនាគតដែរ កសាងជីវិតខ្លួន គ្រួសារខ្លួន និងសង្គមជាតិខ្លួនអោយបានប្រសើរ ។ ទាំងអស់គ្នាធ្វើសកម្មភាពរស់រវើក ។ ប៉ុន្តែសេចក្តីស្លាប់មកដល់រូបមនុស្សដូចអង្គត់អុស ! ហើយមិនគ្រាន់តែដូចអង្គត់អុស ឬដុំថ្មប៉ុណ្ណោះទេ ទុកត្រឹមតែបីថ្ងៃប៉ុណ្ណោះ ( បើស្លាប់ម្នាក់ឯងកណ្តាលព្រៃស្ងាត់ ) រូបនេះហើមប៉ោងរលេះរលួយស្អុយគគ្រុក ដង្កូវរុករវើក! ឱអនិច្ចារូបគេ រូបយើង ! ពេលនៅមានជីវិត នាំគ្នាត្រេកត្រអាលគ្រប់បែបយ៉ាងស៊ីដេក ធ្វើការ សំរាក លំហែសញ្ជឹងគិតពេលសេចក្តីស្លាប់មកដល់ លែងដឹងអ្វីទាំងអស់ !

យើងទាំងអស់គ្នាដឹងអនាគតជាតិ ឬជាតិក្រោយរបស់យើងមានលក្ខណៈដូចម្តេចទេ ? រួចយើងទាំងអស់គ្នា អត់ទាំងបានដឹងថា ដូនតាយើងដែលស្លាប់ទៅហើយនោះ គាត់ស្លាប់ទៅសូន្យ ឬទៅចាប់ជាតិនៅឯភូមិស្រុកណា ? ឯប្រទេសណា ? ឋានណាទេ ? ។

ពុទ្ធសាសនា បានប្រៀបប្រដៅថា : មានរូប គឺមានទុក្ខ

ព្រោះរូបរាងកាយ គឺជាជម្រុក នៃតណ្ហា តណ្ហា គឺជាហេតុ នៃសេចក្ដីទុក្ខ ។ សេចក្ដីទុកនេះជា " **សច្ចភាព** " មនុស្សយើងទាំងអស់គ្នានេះមានអ្នកណាមួយ ដែលមិនមានទុក្ខ អ្នកខ្លះមានទុក្ខព្រោះរឿងនេះ អ្នកខ្លះមានទុក្ខព្រោះរឿងនោះ រឿងខ្វះខាតក្នុងការរស់ នៅ រឿងរៀនសូត្រ ឬធ្វើអ្វីៗ មិនបានសំរេច រឿងវិបត្តិគ្រួសារ រឿងវិបត្តិសង្គម រឿងអាក្រក់រាប់សែនជំពូក ចេញមកពីបាតុភូតធម្មជាតិ រឿងជម្ងឺដំកាត់ រឿងចាស់ទ្រុឌទ្រោម រឿងពិកលពិការ រឿងស្លាប់ ។ ទុក្ខធំជាងគេ ដែលអោយមានភ័យតក់ស្លុតជាងគេ គឺ សេចក្ដីស្លាប់នេះឯង ដែលមនុស្សទាំងអស់គ្មានអ្នកណាមួយចៀសផុតឡើយ ។

" មានរូបពិតជាមានទុក្ខ " ។

" ទុក្ខព្រោះមិនបានដូចបំណង ទុក្ខព្រោះហៃលឆ្ងងការព្រាត់ប្រាស់ ទុក្ខព្រោះជម្ងឺ ទុក្ខព្រោះចាស់ ទុក្ខព្រោះដឹងច្បាស់ថាត្រូវស្លាប់ " មានរូបពិតជាមានទុក្ខមែន ប៉ុន្តែសេចក្ដីស្លាប់ក៏មិនទាន់អស់ទុក្ខដែរ ព្រោះអ្វី ? ព្រោះមនុស្សម្នាក់ៗមានរូបរាងកាយផងមានអត្ដ័ន ឬបដិសន្ធិវិញ្ញាណផង ។ រូបរាងកាយគ្រាន់តែជាសំបកក្រៅ ឬ សាកអសុភប៉ុណ្ណោះ ។ អត្ដ័ន ឬបដិសន្ធិវិញ្ញាណមិនចេះស្លាប់ទេ កាលណារូបរាងកាយត្រូវបែកធ្លាយដោយប្រការឯណានិមួយនោះ អត្ដ័ន ឬបដិសន្ធិវិញ្ញាណនេះទៅ

ចាប់កំណើតជាថ្មីទៀត ។ សេចក្ដីស្លាប់ គឺគ្រាន់តែជាការផ្លាស់ប្ដូររូបរាងកាយប៉ុណ្ណោះ ។

បើបដិសន្ធិវិញ្ញាណនេះទៅចាប់កំណើតថ្មី មានរូបរាងកាយថ្មីទៀត រូបរាងកាយថ្មីនេះ ក៏ជួបនឹងទុក្ខទៀត ព្រោះមានរូបត្រូវតែមានទុក្ខជាដរាប ។

ពុទ្ធសាសនាយើងសំដែងថា " ស្លាប់ហើយកើតទៀត " សេចក្ដីស្លាប់គ្រាន់តែជាការចេញចាករូបចាស់ ដែលបែកធ្លាយដោយប្រការណាមួយ ដើម្បីទៅចាប់កំណើតក្នុងរូបមួយថ្មីទៀត ប៉ុណ្ណោះមានរូប គឺមានទុក្ខ ប្រសិនបើមានសុខខ្លះ ក៏ជាសុខលាយឡំដោយទុក្ខ មានតែព្រះនិព្វានទេ ទើបចាកផុតក្ដីទុក្ខ ។ វិធីឡើងទៅកាន់ព្រះនិព្វាន ជាវិធីដ៏វែងឆ្ងាយ ហើយពិបាកនឹងទៅដល់ ។ ប៉ុន្តែសូមពុទ្ធមាមិកជនកុំអស់សង្ឃឹម ! ពីនេះទៅដល់ព្រះនិព្វានមានស្ថានីយ៍ ផ្ដល់សេចក្ដីសុខច្រើនជំនាក់ការដែរ។ អ្នកសន្សំកុសលផលបុណ្យបានតិច អាចបានកើតក្នុងឋានមនុស្សលោកនេះដដែលទៀត មានរូបស្អាត មានជីវភាពសុខស្រួលជាងជីវិតបច្ចុប្បន្ន ។

អ្នកដែលសន្សំកុសលផលបុណ្យបានបង្គួរ បានទៅកើតឋានសួគ៌ជាន់ទាប ។ អ្នកដែលបានកសាងសន្សំកុសលផលបុណ្យបានច្រើនបានទៅកើតឯឋានសួគ៌ជាន់ខ្ពស់ ។ ស្ថានសួគ៌

មានច្រើនជាន់ណាស់ ។ នាំគ្នាខំកសាងសន្សំផលបុណ្យទៅ បើមិនបានទៅដល់ព្រះនិព្វាន ក៏បានទៅសោយសុខនៅឯស្ថានសួគ៌ដែរ ឬយ៉ាងហោចណាស់ក៏បានសោយសុខក្នុងមនុស្សលោកនេះក្នុងជាតិខាងមុខដែរ ។

អស់លោកអ្នក ពុទ្ធសាសនិកជនទាំងឡាយ ! មនុស្សយើងមានតណ្ហាលោភលន់ច្រើនណាស់ បាននេះហើយចង់បាននោះទៀតបានមួយហើយចង់បានពីរ ! បានពីរហើយ ចង់បានបី...... មិនចេះឆ្អែតដូចសមុទ្រ មិនចេះឆ្អែត នឹងទឹកជំនន់ ។ ក្នុងលោកនេះ ទោះជាអ្នកខ្លះដែលមានជីវភាពខ្ពង់ខ្ពស់រុងរឿងហើយ ក៏នៅតែប្រាថ្នាអោយជាតិក្រោយបានរុងរឿងជាងនេះបានសុខជាងនេះទៀត ។ ប៉ុន្តែមានអ្នកខ្លះដើរប្រព្រឹត្តតែអំពើបាប ជិះជាន់ សង្កត់សង្កិនគេ កាប់សំលាប់គេ ហើយក៏តាំងប្រាថ្នាចង់បានសុខ ប្រាថ្នាឡើងស្ថានសួគ៌ដែរ ។

នៅប្រទេសក្រិច រឿងពិតពីជនជាតិ ថ្រាស់ មានទស្សនៈមួយយ៉ាងចម្លែក ។ កាលណានៅក្នុងផ្ទះណាមួយមានស្រីម្នាក់កំពុងឈឺពោះឆ្លងទន្លេ មនុស្សទាំងអស់ក្នុងផ្ទះនោះនាំគ្នាអង្គុយយំ កាលណាស្រីនោះឆ្លងទន្លេរួចហើយ ពួកអ្នកជិតខាងមកចោមរោមមើលទារក ឬទារិកានោះដោយទឹកមុខព្រួយបារម្ភស្រងូតស្រងាត់ ។ ផ្ទុយទៅវិញ បើផ្ទះណាមានមនុស្សស្លាប់គេ

ឃើញមនុស្សទាំងអស់ក្នុងផ្ទះនោះមានទឹកមុខរីករាយ រួចអ្នកជិតខាងដែលបានមក ជួយយកសាកសពទៅកប់មានទឹកមុខសប្បាយរីករាយដែរ គេកប់ខ្មោចបណ្ដើរ ច្រៀងរាំសប្បាយបណ្ដើរ ។

ជនជាតិផ្រាស់មានទស្សនៈថា មានរូបគឺមានទុក្ខ គេនាំគ្នាឃុំ អាណិតទារក ទារិកា ដែលត្រូវរែកពុននូវទុក្ខក្នុងជីវិត។ ដែលគេនាំគ្នាច្រៀងរាំបណ្ដើរ កប់ខ្មោចបណ្ដើរនោះ ព្រោះគេយល់ថា អ្នកស្លាប់ទៅហើយ បានផុតពីទុក្ខហើយ ។ គេគ្មានតក់ស្លុតចំពោះសេចក្ដីស្លាប់ទេ ។

ក្នុងលោកយើងនេះ មនុស្សស្លាប់គ្រប់វិនាទី គ្រាន់តែការស្លាប់នេះដោយហេតុផ្សេងៗគ្នា ស្លាប់ដោយចាស់ជរា ស្លាប់ដោយជម្ងឺ ស្លាប់ដោយគ្រោះថ្នាក់ ស្លាប់ដោយសំលាប់ខ្លួនឯង ស្លាប់ដោយឈ្លោះប្រកែកគ្នា ប្រយុទ្ធគ្នា និងស្លាប់ដោយពលិកម្មបរិជាតិការពារជាតិ ក្នុងពេលប្រទេសជាតិមានអាសន្ន ខ្មាំងបរទេសចូលឈ្លានពាន យុទ្ធជនស្នេហាជាតិបានធ្វើពលិកម្មជីវិតទៅប្រយុទ្ធនិងមារសត្រូវ ដើម្បីការពារជាតិមាតុភូមិផងខ្លួន ។ តាមផ្លូវលោកបច្ចុប្បន្នស្លាប់ក្នុងសមរភូមិបំរើជាតិ គឺស្លាប់ក្នុងកិត្តិយសខ្ពង់ខ្ពស់ក្រៃលែង ។

រស់នៅក្នុងភាពក្រខ្សត់លំបាកវេទនា ខ្វះស្បៀងអាហារ

ខ្វះជំរក ខ្វះសំលៀងបំពាក់ ឬរស់នៅដោយមានទុក្ខព្រួយ វិបត្តិគ្រួសារ ឬរស់នៅក្រោមអំណាចរឹបជាន់របស់គេខ្លាំងពេក មនុស្សមានការធុញថប់ នឹងជីវិតក៏ស្រែកហៅរកសេចក្ដីស្លាប់ : ឱ ! សេចក្ដីស្លាប់ តែកុងចំណាប់ នៃនាវាអើយ ! ដល់ពេលវេលា លើយុថ្កាហើយ យើងថប់ឥតស្បើយ រស់ក្នុងស្រុកនេះ ។ ឆាប់ឡើងមច្ចុរាជ ! លោកមានអំណាច កុំនៅក្រអេះ ដឹកនាំនាវា ចេញមកស្រុកនេះ ធុញថប់អ្វីម្ល៉េះ គស់យើងចេញទៅ ! ។

ដោយមានជម្ងឺប្រចាំកាយ ឈឺរ៉ាំរ៉ៃមើលមិនជា ដោយរស់ត្រាំត្រែងក្នុងជម្ងឺពិបាកពេក មនុស្សក៏ស្រែកហៅរកសេចក្ដីស្លាប់ដែរ : ឱ ! មច្ចុរាជ ខ្ញុំគោរព លោកជាប្រភព នៃក្ដីសុខ លោកជាគ្រូពេទ្យ កំចាត់ទុក្ខ ជាមេថាសុករបស់ខ្ញុំ ! ។ លោកអើយ ! មកយកខ្ញុំទៅឆាប់កុំអោយឈឺចាប់នៅជាប់ងុំ ទេវមច្ចុរាជអាណិតខ្ញុំ ខ្ញុំសុំអង្វរ យកខ្ញុំទៅ ! ។

ដោយឈឺចាប់ខ្លាំងពេក ដោយលំបាកវេទនាពេក មនុស្សហៅរកសេចក្ដីស្លាប់ ។ ប៉ុន្តែបើឃើញសេចក្ដីស្លាប់មកដល់ហើយមនុស្សភិតភ័យណាស់ អត់ចង់ស្លាប់ទេ . សុខចិត្តរស់តទៅទៀត ទោះបីរស់ក្នុងទុក្ខវេទនាយ៉ាងណាក៏ដោយ ។

តទៅនេះ ( អាត្មាភាព ) សូមលើករឿងល្បើកមួយឈ្មោះ " សេចក្ដី ស្លាប់ និងអ្នកកាប់អុស " មកសំដែង ដែល

មានអត្ថន័យដូចតទៅនេះ : មានបុរសម្នាក់ ប្រកបមុខរបរចិញ្ចឹមជីវិតផ្ទាល់ខ្លួន និងប្រពន្ធកូនដោយការកាប់អុសលក់ តាំងពីវ័យក្មេងរហូតដល់មជ្ឈិមវ័យ ។ មានពេលថ្ងៃមួយនោះ បន្ទាប់ពីគាត់លើកអុសដាក់លើស្មាលី ដើរមកផ្ទះដំណើរទ្រេតទ្រោតខ្នងកោងជូន់ នឹងអុសផង ឃ្លានអាហារផង ក៏ស្រែកថ្ងូរយំតាមផ្លូវ គិតសង្វេគរូបកាយខ្លួន អាត្មាអញតាំងពីកើតមកមិនដែលបានសុខស្រួល នឹងគេទេ ! ជួនកាលអត់អាហារ ហើយធ្វើការគ្មានទំនេរ ពេលខ្លួនឃ្លាន ណាមួយគេកេណ្ឌធ្វើការមួយសែនគ្មាន ទុក្ខរុករានគ្មានពេលល្ហែ គ្មានពេលស្បើយ ។ គិតសព្វគ្រប់ហើយតាកាប់ អុស ក៏ស្រែកហៅ " **មច្ចុរាជ** " អោយមកយកអាយុជីវិតគាត់ ។ ស្រែកហៅច្រើនដងទៅមច្ចុរាជក៏មកដល់ភ្លាមហើយសួរទៅតាកាប់អុសថា : ពុំយហៅអញមានការអីនិយាយមក ! តាកាប់អុសក៏ឆ្លើយទៅមច្ចុរាជថា : អើអញហៅប្រស្លែងមិនហៅលេង ហៅលើកអុសដាក់លើស្មា កុំនៅឈរ ! ជួយអញមក ! អញប្រញាប់ ! ។

សេចក្តីស្លាប់មកដល់ ទុក្ខអំពល់លែងអាប់អួរ តែសុខចិត្តរស់វេទនា គ្រាន់ជាងស្លាប់ គឺប្រញាប់ចាវចនារបស់មនុស្ស ។

មនុស្សចង់រស់មិនចង់ស្លាប់ ភ័យខ្លាចសេចក្តីស្លាប់ ។ កាលណានឹកដល់សេចក្តីស្លាប់ ព្រួយចិត្ត អស់កំលាំងចិត្ត មិនចង់

ធ្វើការរកស៊ីអ្វីទេ ។ ប៉ុន្តែនឹកដល់រឿងដែលខ្លួននៅរស់ នឹកដល់កូនចៅនឹកដល់មនុស្សជំនាន់ក្រោយ យល់ថាត្រូវតែខំប្រឹងប្រែងធ្វើការកសាងសន្សំតទៅទៀត ។

មនុស្សកើតមកត្រូវតែស្លាប់ទៅវិញ ។ ដូច្នេះតាំងពីថ្ងៃកើតរហូតដល់ថ្ងៃលែងរស់ គឺជារយះពេលរបស់សេចក្តីស្លាប់ ។ ដូច្នេះមនុស្សរស់ក្នុងសេចក្តីស្លាប់របស់ខ្លួន ។ ព្រះសម្មាសម្ពុទ្ធទ្រង់អោយភាវនា នឹកគិតដល់សេចក្តីស្លាប់គ្រប់ដង្ហើមចេញចូលថា : **អទ្ធុវំ មេជីវិតំ** សេចក្តីរស់នៅ នៃយើងមិនទៀង **ធុវំ មរណំ** សេចក្តីស្លាប់ទៀង **អវស្សំ មយា មរិតព្វំ** យើងគង់ស្លាប់ដោយពិត **មរណ បរិយោសានំ មេជីវិតំ** សេចក្តីរស់នៅនៃយើង មានសេចក្តីស្លាប់ជាទីបំផុត **ជីវិតំ អទ្ធុវំ ធុវំ មរណន្តិ** សេចក្តីរស់នៅ មិនទៀង សេចក្តីស្លាប់ទៀង ។

**សព្វេ សត្តា** សត្វទាំងឡាយទាំងពួង **មរន្តិ ច** ស្លាប់ឥឡូវនេះផង **មរិសុច** ស្លាប់ហើយផង **មរិស្សរេ** នឹងស្លាប់ឯមុខផង **តថេវាហំ មរិស្សាមិ** យើងនឹងស្លាប់ដូចសត្វទាំងឡាយនោះដែរ **នត្ថិមេ ឯត្ថ សំសយោ** សេចក្តីសង្ស័យនៃយើងក្នុងរឿងស្លាប់នេះគ្មានឡើយ ។

រស់នៅ គឺរស់ក្នុងសេចក្តីស្លាប់រួចទៅហើយ ប៉ុន្តែមាន

អ្នកខ្លះមិនគ្រាន់តែរស់ក្នុងសេចក្ដីស្លាប់ប៉ុណ្ណោះទេ គឺគេរស់ស្លាប់តែម្ដង ។ រស់ស្លាប់គឺ រស់ដូចដើមឈើ រស់ដូចបក្សា បក្សី រស់ដូចម្រឹគី ម្រឹគា ស៊ីដេក ស៊ីដេក រស់យឺតៗ រស់សន្សឹមៗ ។ ផ្ទុយពីមនុស្សរស់ស្លាប់ គឺស្លាប់រស់ ស្លាប់រស់មាន ន័យថា គឺរូបរាងកាយក្លាយទៅជាធូលីដីទៅហើយ ប៉ុន្តែគេនៅរស់ គេត្រូវបានអ្នកផងគោរពនឹករលឹកជានិច្ច អំពីទង្វើរបស់លោក ពីស្នាដៃរបស់លោកដូចជាលោកតាក្រមង៉ុយ សម្ដេចជួនណាត ជាដើម ស្លាប់ទៅមែន ប៉ុន្តែស្នាដៃរបស់លោកនៅរស់ជានិច្ច កិត្តិយសកេរ្តិ៍ឈ្មោះនៅរស់ជានិច្ច ។

កើតជាមនុស្ស ដែលជាសត្វមានសតិសម្បជញ្ញៈ ដឹងខ្លួនថា ត្រូវតែស្លាប់នោះ មនុស្សទាំងឡាយគួរតែរៀបចំខ្លួនប្រាណអោយបានប្រសើរ គួរនាំគ្នាប្រព្រឹត្តតែអំពើល្អ គួរនាំគ្នាកសាងសុខៈទុកអោយមនុស្សជំនាន់ក្រោយ ជាពិសេសទុកសំរាប់ខ្លួនឯងតែម្ដង ។

## គួររៀបចំខ្លួនប្រតិបត្តិតាមវ័យ

ពុទ្ធសាសនា លោកបានចែកវ័យ របស់មនុស្សយើងជា ៣ គឺៈ

១. បឋមវ័យ ( វ័យដំបូង )

២. មជ្ឈិមវ័យ ( វ័យកណ្ដាល )

៣. បច្ឆិមវ័យ ( វ័យចុងក្រោយ )

បឋមវ័យ ចាប់តាំងពីថ្ងៃកើតរហូតដល់អាយុ ២៥ ឆ្នាំ ក្នុងវ័យនេះត្រូវខំប្រឹងប្រែងរៀនសូត្រចំនេះវិជ្ជា និងមុខជំនាញវិជ្ជាជីវៈណាមួយ ដើម្បីចិញ្ចឹមជីវិត ។

មជ្ឈិមវ័យ ចាប់តាំងពីអាយុ ២៦ឆ្នាំ រហូតដល់អាយុ ៥០ឆ្នាំ ក្នុងវ័យនេះត្រូវខំប្រឹងប្រែង ស្វែងរក ទ្រព្យសម្បត្តិសំរាប់ចិញ្ចឹមជីវិតបុត្រ ភរិយា និងខ្លួនឯង ។

បច្ឆិមវ័យ ចាប់តាំងពីអាយុ ៥១ ឆ្នាំ រហូតដល់ថ្ងៃស្លាប់ ក្នុងវ័យនេះ ត្រូវខិតខំកសាងខ្លួន ប្រព្រឹត្តតែអំពើល្អ ឬរៀបចំខ្លួនប្រាណដើម្បីស្លាប់ ។ ឈានចូលដល់ បច្ឆិមវ័យ ត្រូវគិតថា អាត្មាអញ រយៈពេលរស់នៅមានតិចណាស់ មិនយូរប៉ុន្មានទេ មច្ចុរាជនឹងមកយកជីវិតអាត្មាអញ ហើយ ! ។ ដូច្នេះត្រូវតំកល់ខ្លួនអោយស្ថិតនៅក្នុងពុទ្ធោវាទ ៣ យ៉ាង :

**១. សព្វបាបស្ស អករណំ** មិនធ្វើនូវអំពើបាបទាំងពួង

**២. កុសលស្សូបសម្បទា** ត្រូវញ៉ាំងកុសលអោយដល់ព្រមគឺអោយធ្វើបុណ្យគ្រប់យ៉ាង

**៣. សចិត្តបរិយោទបនំ** អោយជំរះសន្តានចិត្តអោយស្អាតផូរផង់ ចាកគ្រឿងសៅហ្មងចិត្តមាន **លោភៈ ទោសៈ មោហៈ** ជាដើម ។

**ធម្មទេសនា** សំដែងអំពី **មរណៈ** ក៏ល្មមសមគួរតាម

ពេលវេលា នឹងបញ្ចប់ហើយ ! តែមុននឹងបញ្ចប់អាត្មាភាពសូម ប្រមូលនូវបុញ្ញរាសីកុសល គឺកំនរបុណ្យ ដែលកើតឡើងនៅ ពេលនេះជាបឋមសូមឧទ្ទិសជូនចំពោះ......ដែលបានធ្វើមរណ កាលទៅកាន់លោកខាងមុខហើយនោះ សូមបានទទួលនូវឥដ្ឋ មនុញ្ញផល និងបានទៅបដិសន្ធិក្នុងសុគតិភពកុំបីឃ្លៀងឃ្លាត ឡើយ ។

សូមសាធុជន ញាតិញោមទាំងឡាយ បានទទួលនូវផលា និសង្សនេះ តាមសេចក្តីប្រាថ្នារៀង១ខ្លួន អនាគតជាតិកើតក្នុងទី ណា១ ជាតិណា ១ ក៏សូមអោយមានប្រាជ្ញាដូចព្រះសារីបុត្ត ចេះ ចាំធម៌យ៉ាងមុះមុត ដូចព្រះមហាអានន្ទ មានសម្បត្តិទ្រព្យធន ធាន រាប់ពាន់លានកោដិ ដូចសេដ្ឋីអនាបិណ្ឌិត ល្អរូបល្អរាងល្អ ឫក ប្រកបដោយបញ្ចពិធកល្យាណី ដូចនាងស្រីវិសាខា មាន អាយុយឺនយូរដូចព្រះមហាកស្សប ប្រាថ្នាដប់ បានដប់ ប្រាថ្នាជា ព្រះពុទ្ធមាតា ពុទ្ធបិតា ឬអគ្គសាវក អគ្គសាវិកាណា១ ក៏សូមឱ្យ បានសំរេចដូចសេចក្តីប្រាថ្នា កើតជាតិណា១ សូមជួប ជីតាជីដូន ប្អូនបង ជិតឆ្ងាយ ម្តាយឱពុក ជួបនឹងព្រះរតនត្រ័យគុណកែវ ទាំង ៣ តាមសេចក្តីបំណង បើប៉ងសម្បត្តិទាំង ៣ គឺសម្បត្តិ មនុស្ស សម្បត្តិទេពតា សម្បត្តិព្រះនិព្វាន ក៏សូមអោយបាន សំរេច ។ **យំ យំ ឥច្ឆិតំ តំ តំ សមិជ្ឈតុ** លោកអ្នកមាន

ប្រាថ្នាយ៉ាងណា ក៏សូមអោយបានសំរេច តាមសេចក្តីប្រាថ្នា នោះៗកុំបីឃ្លាតឡើយ ។

**អយំ ធម្មទេសនា និដ្ឋិតា** ព្រះធម៌ទេសនា ដែលបាន សំដែងមកនេះ ក៏សូមបញ្ចប់តែប៉ុណ្ណោះឯង **ឯវំ** ! ៚

ព.ស ២៥១៤

គ.ស ១៩៧០

ស្រាវជ្រាវ និង រៀបរៀង

ដោយ ភិក្ខុ **ខាត់-សាន់**

វត្តត្រពាំងធំ ឃុំពោធិអង្រ្គង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

# អានិសង្សបុណ្យខ្មោច (១)

មនុស្សសត្វដែលកើតមកក្នុងលោក តែងត្រូវទុក្ខ ៤ កង គ្របសង្កត់ :

១. ជាតិ ទុក្ខ ទុក្ខព្រោះកើត

២. ជរាទុក្ខ ទុក្ខព្រោះចាស់

៣. ព្យាធិទុក្ខ ទុក្ខព្រោះឈឺ

៤. មរណទុក្ខ ទុក្ខព្រោះស្លាប់

បណ្ដាទុក្ខទាំង ៤ កងនោះ ទុក្ខព្រោះស្លាប់ ជាទុក្ខធំខ្លាំងជាងគេទាំងអស់ ព្រោះគ្មានអ្នកណាម្នាក់ចង់ស្លាប់សោះចង់តែរស់គ្រប់គ្នា ទោះបីស្លាប់ខ្លួនឯង ឬស្លាប់ប្រពន្ធ កូន ម្ដាយ ឳពុក បងប្អូន ជីដូន ជីតា មា មីង ញាតិសន្ដានក៏កើតទុក្ខទាំងអស់គ្នា ប្លែកតែច្រើន និងតិចប៉ុណ្ណោះ ។ វៀរតែព្រះអរិយបុគ្គល ដែលបានសំរេចព្រះអរហត្ត ជាព្រះអរហន្តអស់កិលេសតណ្ហាហើយ ទើបលោកមិនខ្លាចស្លាប់ លោកត្រលប់ជាខ្លាចកើតវិញ ព្រោះលោកយល់ថា កើតនាំអោយចាស់ នាំអោយឈឺ នាំអោយស្លាប់ ស្លាប់ហើយកើត កើតហើយស្លាប់ សាចុះសាឡើង វិលវល់ក្នុងវដ្ដសង្សារ ។

ឯមនុស្សបុថុជ្ជន មានកិលេសក្រាស់ គ្មាននរណាម្នាក់

មិនខ្លាច ស្លាប់ទេ ទោះបីជាមនុស្សជរាពិការយ៉ាងណាក៏ចង់រស់ដែរ ។

សេចក្តីស្លាប់ បើប៉ះពាល់លើគ្រួសារណាមួយហើយ គ្រួសារនោះតែងតែមានទុក្ខព្រួយ យ៉ាងក្រៃលែងរកអ្វីប្រៀបពុំបាន ។

ក្នុងពេលមរណទុក្ខមកគ្របសង្កត់លើគ្រួសារណាគ្រួសារនោះរមែងតែនឹកដល់ញាតិមិត្ត ចង់អោយគេជួយមកសំរាលទុក្ខ ទំនុកបំរុងបុណ្យសពរបស់ខ្លួន ។ បើមានញាតិមិត្តមកជួយឈឺឆ្អាលគ្រួសារនោះតែងមានចិត្តសោមនស្សនឹកអរគុណគេជាខ្លាំង គឺដូចជាគេមកជួយរំលែកសេចក្តីទុក្ខអោយធូរស្រាលខ្លះ ។ ហេតុហ្នឹងហើយបានជាលោក ។

សំដែងថា សប្បុរស ដែលមានចិត្តសទ្ធា និងមេត្តាបាន ជួយឈឺឆ្អាលសំរាលទុក្ខគេក្នុងបុណ្យសព គឺបុណ្យខ្មោច បាន អានិសង្សច្រើនណាស់ ដោយហេតុ ២ យ៉ាងគឺ:

១. ដោយបានជួយរំលែកទុក្ខគ្រួសារ នៃសព

២. ដោយកើតសេចក្តីសង្វេគ ។

ហេតុទី ១ ដែលថាអ្នកបានជួយឈឺឆ្អាល ជួយរំលែកសេចក្តីទុក្ខ ជួយទំនុកបំរុងបុណ្យសព បានផលច្រើននោះព្រោះ

---

១. ដកស្រង់ចេញពី អានិសង្សសាមសិប របស់ឧត្តមប្រឹជា **ចាប ពិន** ។

គេធ្វើត្រូវលើសង្គហវត្ថុ ៤ យ៉ាងគឺ :

១. **ទាន** : ការឱ្យទាន គឺបានជួយចាប់កុសលក្នុងបុណ្យសព ។

២. **បិយវាចា** : បានពោលពាក្យល្អ គឺបានជួយសូត្រធម៌ជាដើម ។

៣. **កល្យាណមិត្តតា** ភាពជាមិត្តល្អ គឺបានជួយឈឺឆ្អាលមិត្ត ។

៤. **សមជីវិតា** ភាពជាអ្នកមានជីវភាពស្មើ គឺទុកការព្រួយរបស់មិត្ត ដូចទុក្ខព្រួយរបស់ខ្លួន ។

ជនដែលបានជួយឈឺឆ្អាលសំរាលទុក្ខ ដល់អ្នកដែលមានទុក្ខ រមែងមានគេជួយឈឺឆ្អាលខ្លួនវិញ ទាំងជាតិនេះ ទាំងជាតិមុខ ។ ព្រោះត្រូវនឹងខេមរសុភាសិតថា: "ចិត្តជា ទាន់គ្រាក្រសម្បុរល្អ ក្នុងខែកក្ដិក" ហើយត្រូវ នឹងពុទ្ធភាសិតថា "អ្នកធ្វើអំពើល្អ តែងបានទទួលផលល្អ" នេះឯង ។

ហេតុទី ២ ដែលថា ការជួយសពកើតសេចក្ដីសង្វេគបានផលច្រើននោះ ព្រោះសេចក្ដីសង្វេគជាប្រភពនៃបុណ្យ ដូចលោកពោលថា: ហេតុកើតបុណ្យមាន ៣ យ៉ាងគឺ :

១. **បសាទោ** សេចក្ដីជ្រះថ្លា

២. **សង្វេគោ** សេចក្ដីស្លុតចិត្ត

៣. **តេសុចរិតា** សេចក្ដីប្រព្រឹត្តល្អដោយទ្វារទាំង ៣ គឺ កាយ វាចា ចិត្ត ។

បណ្ដាហេតុកើតបុណ្យ ៣ យ៉ាងនេះ ត្រង់ហេតុទី ២ ថា សង្វេគោ សេចក្ដីស្លុតចិត្តក្នុងបុណ្យសពនោះ ត្រូវជាបំផុតព្រោះធម្មតាមនុស្សឃើញសព បានជួយបុណ្យសពនោះបើមិនសង្វេគច្រើនក៏តិចដែរ អ្នកដែលសង្វេគតិច ឬឆាប់ បានផលតិច សង្វេគច្រើន ឬយូរបានផលច្រើន ប៉ុន្តែអ្នកដែលបានឃើញសាកសព ឬឃើញ គេហែសពជូនកាលសង្វេគ ជូនកាលមិនសង្វេគក៏មានអ្នកដែលមិនសង្វេគ ព្រោះមិនគិតដល់ព្រះត្រៃលក្ខណ៍ គឺ: **អនិច្ចំ ទុក្ខំ អនត្តា** បើគិតដល់ព្រះត្រៃលក្ខណ៍គង់មានសង្វេគខ្លះពុំខាន ។

ការគិតដល់ត្រៃលក្ខណ៍សញ្ញា អសុភសញ្ញា សង្វេគសញ្ញា សូម្បីតែមួយស្របក់ ក៏បានជាឧបនិស្ស័យ អាចញុំាងអនាគតរបស់ខ្លួនឱ្យបានសំរេចមគ្គផល ដូចរឿងព្រះចូឡបន្ថកត្ថេរ ដែលបានសំរេចមគ្គផល ព្រោះឧបនិស្ស័យ នៃការគិតដល់សញ្ញា ទាំង ៣ នោះតែមួយស្របក់ពីបុព្វជាតិ ។

▦ ▦ ▦

# រឿងព្រះចូឡបន្ថកត្ថេរ

កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានព្រះថេរៈ មួយអង្គឈ្មោះចូឡបន្ថកៈ ជាប្អូនព្រះមហាបន្ថកៈ ។ ព្រះថេរៈជាបងចង់ឱ្យប្អូនបានចេះដឹងធម៌វិន័យ ក៏ដាស់តឿនឱ្យខំរៀន តែទោះបីព្រះចូឡបន្ថកៈ ខំរៀនយ៉ាងណាក៏មិនចេះសោះ ព្រោះមានពុំនៀរកាលពីជាតិមុនលោកជាអ្នកចេះដឹង បាននិយាយបន្តុះបង្អាប់ភិក្ខុល្ងង់ ។

ថ្ងៃមួយគហបតីម្នាក់ បាននិមន្តព្រះសម្មាសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃច្រើនរូប មានព្រះមហាបន្ថកៈ ជាដើមទៅឆាន់ ។

ព្រះមហាបន្ថកៈ មានឋានៈជាភត្តុទ្ទេសក៏ ជាអ្នកចាត់ភិក្ខុឱ្យទៅឆាន់ តាមចំនួនដែលទាយកនិមន្ត គ្រានោះព្រះមហាបន្ថកៈ មិនចាត់ព្រះចូឡបន្ថកៈឱ្យទៅទេ ។

វេលាព្រះមហាបន្ថកៈ និងភិក្ខុឯទៀតទៅហើយ ព្រះចូឡបន្ថកៈខឹងណាស់ ដើរចេញតាមទ្វារវត្តទៅក្រៅប្រាថ្នានឹងសំលាប់ខ្លួន ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ជ្រាប ទ្រង់យាងទៅឈរស្កាត់ពីមុខ។ ដោយទ្រង់ជ្រាបថា កាលពីជាតិមុនព្រះចូឡបន្ថកៈកើតជាព្រះរាជាមួយព្រះអង្គវេលាទ្រង់យាងប្រទក្សិណព្រះនគរទ្រង់បែកញើស ចេញជោកព្រះភក្ត្រ ទ្រង់យកកន្សែងថ្មី សស្អាត

ផ្ចិតមួយរំពេច ក៏ប្រឡាក់បន្ទិលភ្លាម ទ្រង់ពិចារណាថា "ឱរូបកាយរបស់មនុស្សសត្វជាទីប្រជុំចុះនូវធូលី " ហើយទ្រង់នឹងសង្វេគស្លុតព្រះទ័យយ៉ាងខ្លាំង ។ ព្រះរាជានោះ គឺព្រះចូឡ-បន្ថកៈ នេះឯង ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបឧបនិស្ស័យនេះ ទ្រង់ហុចកន្សែងដៃតូចៗ ទៅព្រះចូឡបន្ថកៈ ដោយព្រះបន្ទូលថា "ចូរអ្នកយកកន្សែងនេះទៅកាន់ឈ្មី ហើយភាវនាថា " **រជោហរណំៗ** ជាទីប្រជុំចុះនៃធូលីៗ " ។

ដោយឧបនិស្ស័យ ដែលកាលពីបុព្វជាតិ បានគិតសង្វេគដល់រូបកាយតែមួយស្របក់ប៉ុណ្ណោះ ព្រះចូឡបន្ថកៈ យកកន្សែងទៅកាន់ឈ្មីពិចារណាតែមួយស្របក់ ក៏បានសំរេចព្រះអរហត្តព្រមទាំងអភិសញ្ញាសមាបត្តិ ៦ មានមនោមយិទ្ធិ ( ឫទ្ធិសំរេចតាមចិត្ត អាចនិម្មិត្តរូបកាយជាអ្វីក៏បាន ) ជាដើមហើយលោកនិមិត្តជាភិក្ខុពេញវត្ត ។

វេលាព្រះជាម្ចាស់យាងទៅដល់ផ្ទះគបតី ទ្រង់មានព្រះបន្ទូលឱ្យទៅនិមន្ត ព្រះចូឡបន្ថកៈមក លុះអ្នកបំរើទៅនិមន្តឃើញភិក្ខុមីរដេរដាស ពាសពេញវត្ត អង្គខ្លះធ្វើនេះ អង្គខ្លះធ្វើនោះ សួរថា "លោកម្ចាស់អង្គណាឈ្មោះចូឡបន្ថកៈ ?" ។ ភិក្ខុ

ទាំងនោះឆ្លើយថាៈ "អាត្មាឈ្មោះចូឡបន្ថកៈៗ" ទាំងអស់ ។ អ្នកបំរើមិនដឹងជានិមន្តអង្គណា ក៏ទៅក្រាបទូលវិញតាមដំណើរនោះ ។ ព្រះអង្គមានព្រះបន្ទូលថា " ចូរទៅម្តងទៀត បើឮឈ្មោះថា ចូឡបន្ថកៈគ្រប់រូប ត្រូវចាប់ដៃមួយរូបឱ្យជាប់ ហើយនិមន្តមកចុះ បានហើយ " ។

លុះអ្នកបំរើទៅនិមន្តម្តងទៀត ចាប់ដៃភិក្ខុមួយរូបតាមព្រះពុទ្ធដីកា ភិក្ខុនិម្មិតទាំងប៉ុន្មានក៏បាត់អស់ នៅសល់តែព្រះចូឡបន្ថកៈមែនទែនមួយរូប ហើយអ្នកបំរើនិមន្តមកលោកឆាន់ជាមួយភិក្ខុទាំងពួង ។

លុះសំរេចភត្តកិច្ចហើយ ព្រះពុទ្ធជាម្ចាស់ត្រាស់ហើយប្រើព្រះចូឡបន្ថកៈ ឱ្យសំដែងធម៌អនុមោទនាទាន ។ ព្រះចូឡ-បន្ថកៈ ក៏សំដែងធម៌អនុមោទនាយ៉ាងពីរោះអស្ចារ្យ នាំឱ្យពួកពុទ្ធបរិស័ទបានស្តាប់នៅពេលនោះ ស្ញើចសរសើរយ៉ាងក្រៃលែង ។

សេចក្តីអស្ចារ្យទាំងនេះ កើតមកពីការគិតពិចារណាដល់សេចក្តីមិនស្អាតរបស់រូបកាយ ហើយមានសេចក្តីសង្វេគស្លុតចិត្តមួយស្របក់ក្នុងជាតិមុននោះឯង ។

ហេតុនេះសាធុជនអ្នកបានឃើញសព បានជួយទំនុកបំរុងបុណ្យសព បានជួយហែសពវេលាណា គួរពិចារណា ឱ្យ

កើតត្រៃលក្ខណ៍សញ្ញា អសុភសញ្ញា និងសង្វេគសញ្ញាវេលា នោះ ទោះបីតិចក្តី ច្រើនក្តីឱ្យបានខ្លះកុំខាន គ្រាន់បានឧបនិស្ស័យ ដូចព្រះចូឡបន្ថកៈថេរចុះ ។ ឯវំ ចប់ដោយសង្ខេប ។

❋❋❋❋❋
❋❋❋
❋

# ប្រវត្តិឆាកបង្សុកូល

ឆាកបង្សុកូល គឺជាកិច្ចរបស់ព្រះសង្ឃក្នុងព្រះពុទ្ធសាសនា ។

ពាក្យថាឆាកបង្សុកូល ចែកជាពីរបទ គឺឆាក ១ បទ បង្សុកូល ១ បទ

. ឆាកប្រែថា : ទាញយកឱ្យឃ្លាតចាកទី ឱ្យដាច់ចេញពីគ្នា ។

. បង្សុកូលប្រែថា : សំពត់ជិតប្រលាក់ដោយធូលី រីដោយមន្ទិល ។

រួមសព្ទទាំងពីរថា : "**ឆាកបង្សុកូល**" (ខ្លះថាឆាកមហាបង្សុកូល) ប្រែថា : ទាញយកនូវសំពត់ដែលជិតប្រលាក់ដោយធូលី រីដោយមន្ទិល ។

តាមវិនយប្បញ្ញត្តិ សំពត់ដែលភិក្ខុគួរបង្សុកូលយកនោះមានពីរយ៉ាងគឺ :

១. សំពត់ ស ដែលគេចោលនៅគំនរសំរាម ប្រលាក់សៅហ្មងដោយអាចម៍ដី ដោយធូលី ។

២. សំពត់ ស្នប ដែលគេរុំសាកសពចោលនៅព្រៃស្មសាន ។

បណ្ដាសំពត់ទាំងពីរនេះ ភិក្ខុបានបង្សុកូលយកសំពត់ណាមួយមកដេរប៉ះផ្សំគ្នា ធ្វើជាចីវរប្រើប្រាស់ចីវរនោះហៅថា "ចីវរបង្សុកូល គឺចីវរឥតម្ចាស់ ។

កាលព្រះពុទ្ធជាម្ចាស់ ទើបនឹងត្រាស់ដឹងថ្មីៗ ទ្រង់ឱ្យភិក្ខុប្រើតែចីវរបង្សុកូលគ្រប់រូប សូម្បីតែតួរព្រះអង្គ ក៏ទ្រង់ប្រើតែចីវរបង្សុកូលដែរ ។ លុះក្រោយមក គ្រូពេទ្យឈ្មោះ **ជីវកកោមារភច្ច** ប្រគេនកោសេយ្យភស្ត្រ (សំពត់សូត្រ) ចំពោះព្រះអង្គ ទើបទ្រង់អនុញ្ញាតឱ្យភិក្ខុ ប្រើប្រាស់ "គហបតីចីវរ" គឺចីវរមានម្ចាស់ ។

ធាកបង្សុកូលនេះ មានពីរយ៉ាងគឺ ធាកបង្សុកូលមនុស្សរស់ ១ ធាកបង្សុកូលមនុស្សស្លាប់ ១ ។

១. ធាកបង្សុកូល មនុស្សរស់នោះ គឺគេយកសំពត់ទៅដាក់លើមនុស្សរស់នោះ ហើយភិក្ខុទៅទាញសំពត់នោះ ដោយសូត្រធម៌ថា :

**អចិរំ វតយំ កាយោ បឋវឹ អធិសេស្សតិ ឆុឌ្ឌោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។**

ប្រែថា: "កាយនេះមិនយូរប៉ុន្មានឡើយ តែមានវិញ្ញាណទៅប្រាស ហើយជាកាយគឺគេបោះបង់ចោល ក៏នឹងដេកសង្កត់នៅលើផែនដី ដូចជាឧង្កត់ឧសរកប្រយោជន៍គ្មាន " ។

គាថានេះព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រារព្ធរឿងដែលជាដើម

ហេតុ : មានកុលបុត្រម្នាក់ឈ្មោះ តិស្សៈ នៅក្នុងនគរមគធៈ ក្រុងសាវត្ថី បានស្តាប់ព្រះធម៌ទេសនារបស់ព្រះសម្ពុទ្ធ មានសេចក្តីជ្រះថ្លា ក៏ប្រគល់កាយថ្វាយជីវិតបួសក្នុងព្រះពុទ្ធសាសនា លុះកាលកន្លងមក ភិក្ខុនោះក៏កើតរោគពងបែកពេញខ្លួន មានក្លិនគួរជាទីបដិក្កូលពន់ពេក ភិក្ខុសាមណេរ ដែលធ្លាប់ថែរក្សាព្យាបាលក៏ធុញទ្រាន់រអាចិត្តមិនហ៊ានចូលទៅជិត ។ ទើបព្រះសម្ពុទ្ធ ព្រះអង្គទ្រង់ព្យាបាលរក្សាដោយព្រះអង្គឯង ។ ទ្រង់ដាំទឹកក្តៅឱ្យងូតក៏មាន នាមប្រាកដថា: បូតិគតិស្សត្ថេរ ។ បូតិគតិ-ស្សត្ថេរ លោកមានសេចក្តីរីករាយរោគក្នុងកាយក៏បានជាសះស្បើយទៅ ។ ក្នុងកាលដែលព្រះសម្ពុទ្ធទ្រង់ព្យាបាលនោះ ព្រះអង្គទ្រង់ឱ្យឱវាទដល់ភិក្ខុទាំងឡាយថា: ម្នាលភិក្ខុទាំងឡាយ លោកទាំងឡាយជាអ្នកចេញចាកពីត្រកូលផ្សេងៗគ្នាមកបួសក្នុងសាសនាជាមួយគ្នា បើអង្គណាឈឺចាប់ បើមិនរក្សាគ្នា តើបានអ្នកណានឹងមកបីបាច់រក្សា ? ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាក៏ដោយ បើប្រាថ្នាប្រតិបត្តិតថាគត ចូរប្រតិបត្តិភិក្ខុមានជំងឺជំនួសតថាគតចុះ ។

ចាប់តាំងពីពេលនោះមក ភិក្ខុទាំងឡាយក៏ព្យាបាលជំនួសព្រះអង្គ ។

កាលឥន្ទ្រីយ៍របស់បូតិគតិស្សត្ថេរ នោះសមគួរហើយ

ព្រះសម្ពុទ្ធទ្រង់សំដែងធម៌ទេសនាថា : **អចិរំ វតយំ កាយោ** ព្រះថេរៈ នោះបានទទួលធម៌ទេសនារបស់ព្រះអង្គហើយ ក៏បាន សំរេចព្រះអរហត្តផល ជាចតុបដិសម្ភិទាញាណ ។ ភិក្ខុទាំង ឡាយក្រាបទូលសួរព្រះបរមសាស្តាអំពីហេតុដែលនាំដំបៅ និង សួរអំពីទៅកើតក្នុងទីណាជាដើម ។

ព្រះសម្ពុទ្ធទ្រង់សំដែងអំពីហេតុនោះថា : កាលកន្លងទៅ ហើយ ព្រះសម្ពុទ្ធព្រះនាមកស្សបៈឧប្បត្តិ ឡើងក្នុងលោក កាល នោះឯងបូតិគតិស្សត្ថេរ បានទៅកើតជាព្រានចាប់សត្វរស់មក សំរាប់ចិញ្ចឹមជីវិតកាលបើគាត់ចាប់បានច្រើនមកហើយបរិភោគ មិនអស់គាត់ក៏កាច់ជើងកាច់ស្លាបព្រោះខុក ដើម្បីលក់នឹង បរិភោគបានយូរ ។ សម័យថ្ងៃមួយនោះ ព្រាននោះក៏មាន សេចក្តីជ្រះថ្លា បានថ្វាយបិណ្ឌបាតទានដល់ព្រះខីណាស្រពមួយ ព្រះអង្គ ។ ព្រះសម្មាសម្ពុទ្ធក៏ទ្រង់សំដែងថា ម្នាលភិក្ខុទាំងឡាយ កម្មដែលបានធ្វើក្នុងកាលនោះឯង មកផ្តល់អោយតិស្សៈនេះ ដែលស្អុយពេញខ្លួនបែកទាំងឆ្អឹងផង ដោយផលកម្មដែលកាច់ ឆ្អឹងសត្វទាំងឡាយ ។ ដែលលុះអរហន្តនោះដោយអានិសង្ស ថ្វាយបិណ្ឌបាតទានដល់ព្រះខីណាស្រពនោះឯង ( បង្សុកូល មនុស្សរស់ចប់ ) ។

២. បង្សុកូល មនុស្សស្លាប់នោះគឺ សំពត់ដែលគេបោះ

បង់ចោលនៅលើគំនរសំរាម ជាសំពត់ដែលគេដាច់អាល័យ ដូច ជាសំលោលចាប សេក សំពត់នៅដោយរានផ្សារ រឺសំពត់រុំខ្មោច ជាដើម សំពត់ទាំងអស់នេះឯង ព្រះអង្គទ្រង់អនុញ្ញាត អោយ ភិក្ខុរើសយកមកប្រើតាម សេចក្តីត្រូវការពួកអ្នកមានសទ្ធាលុះ បានឃើញដូច្នេះ ហើយក៏នាំយកសំពត់ថ្មី ទៅចោលនៅទីអសុភ ទីបាំងឆា ហៅថា សំពត់បង្សុកូល ។

លុះកន្លងយូរមក អ្នកមានសទ្ធាបានឃើញ ធ្វើដូច្នោះ ទើបជាបដិកូល ទើបយកសំពត់ទៅគ្របលើមឈូសខ្មោច រឺទាញ ខ្សែខ្មោច ( ខ្សែទូរ ) អំពីខ្មោចហើយដាក់សំពត់លើខ្សែ ភិក្ខុអ្នក បង្សុកូល ពិចារណាដោយគាថា ថា : **អនិច្ចា វត សង្ខារា ខ** ហើយនាំយកសំពត់នោះមក ដើម្បីប្រើប្រាស់ ។ ហេតុនេះ ហើយបានជាគាថានេះ សំរាប់បង្សុកូលមនុស្សស្លាប់ ។

និទានដើមហេតុ : កាលកន្លងទៅហើយ មានភិក្ខុមួយ អង្គឈ្មោះមហាកាល លោកមានចិត្តជ្រះថ្លាពិចារណា នូវអសុភ កម្មដ្ឋាន ក្នុងទីបាំងឆា ។ ថ្ងៃមួយមានគេយកសពស្ត្រីម្នាក់មានរូប ល្អសោភាទើបតែស្លាប់ថ្មីៗ ទៅធ្វើឈាបនកិច្ចក្នុងទីបាំងឆានោះ ភិក្ខុមហាកាល លោកបានពិចារណាថា : **អនិច្ចា វត សង្ខារា......** លោកពិចារណាធម៌នេះដោយយោនិសោមនសិ ការលោកក៏បានសំរេច អរហត្តផល ព្រមទាំងចតុប្បដិសម្ភិទា

ញាណក្នុងកាលនោះឯង ។

ព្រោះហេតុនោះ បានជាគាថានោះជាប់ជាទំនៀមទំលាប់សំរាប់បង្សុកូលមនុស្សស្លាប់រហូតមកដល់សព្វថ្ងៃនេះ ។ ចប់ដោយសង្ខេប ។

## ប្រវត្តទង់ក្រពើ-ទង់ព្រលឹង នៅពេលមានបុគ្គលស្លាប់

•••••••••

នៅគ្រប់ស្រុកក្នុងប្រទេសកម្ពុជា គេតែងនិយមប្រើទង់ក្រពើនិងទង់ព្រលឹង នៅពេលមានបុគ្គលស្លាប់ ។ កាលណាអ្នកជំងឺមានកំលាំងតិចជិតនឹងអស់ខ្យល់ អស្សាសៈ បស្សាសៈហើយលោកអាចារ្យតែងយកសំពត់ស ប្រវែង ៤ ហត្ថ បត់ជាពីរ យកឈើ រឺបន្ទះឬស្សីពីរកំនាត់ដាក់ខ្វែងគ្នា គឺមួយជាដង មួយជាឈើឆ្កាង រួចស៊កក្នុងផ្នត់សំពត់ ហើយចងបង្រួមក្រសោបក្រោយសំរាប់កាន់មានផ្ទាំងបាយថ្មីមួយ ចងបន្តោងភ្ជាប់នឹងដងទង់នោះផង ហើយអាចារ្យសរសេរបាលីនៅលើផ្ទៃទង់នោះថា :

**អាគាយ ចត ឥធំ អយំ តុសិត តចនំ**

**អាគច្ឆន្តិ អសោមិកំ សុញ្ញំ គណ្ហាមិ**

ហើយអាចារ្យលើកទង់នោះ ទៅដាក់នៅក្បាលដំណេក បុគ្គលស្លាប់រួចផ្តាំបុគ្គល ( ខ្មោច ) នោះថា **"ទង់ព្រលឹង"** នេះជាសំបុត្រ ដើរផ្លូវរបស់អ្នកហើយ ចូរអ្នកកាន់អោយជាប់ ដើម្បីធ្វើដំណើរទៅថ្វាយបង្គំព្រះចុឡាមណីចេតិយ ព្រោះអ្នក ទៅតែម្នាក់ឯងគ្មានអ្នកណានាំផ្លូវទេ ។ រួចអាចារ្យក៏ដាក់ឈ្មោះ របស់ខ្លួនក្នុងនាមបញ្ញា ( ១ ) ។

# ប្រវត្តទង់ព្រលឹង

កាលពីអតីតកាលដ៏យូរលង់មានបុរសម្នាក់មានកូនប្រុស មួយជាទីស្រលាញ់ បានសុំលាឱពុកទៅរៀនសិល្បសាស្ត្រឯនគរ តក្កសីលា លុះរៀនចប់ក៏សុំលាអាចារ្យចេញទៅរកគ្រូផ្សេងទៀត ដើម្បីរៀនបន្ថែម ។ លុះដើរទៅបានជួបនឹងព្រះបច្ចេកពុទ្ធមួយ អង្គឃើញ លោកប្រព្រឹត្តល្អតាមរបៀបសមណៈ មាណពនោះ មានចិត្ត ស្រលាញ់ ជ្រះថ្លា ក៏ចូលទៅសុំរៀនក្នុងសំណាក់ព្រះ បច្ចេកពុទ្ធអង្គនោះ ។

ព្រះបច្ចេកពុទ្ធ លោកក៏អោយរៀន ប៉ុន្តែលោកអោយបួសសិន ។

---

១. នាមបញ្ញា គឺជាឈ្មោះ ដែលព្រះឧបជ្ឈាយ៍បានដាក់ឱ្យក្នុងពេលដែល លោកអាចារ្យនោះបានបួសជាភិក្ខុ ឬសាមណេរ ។

( មាណពនោះបួសរួចហើយ លោកបង្រៀនធម៌វិបស្សនាកម្មដ្ឋាន ) ។

នៅរៀនយូរៗទៅមាណពនោះ បានសំរេចពោធិញ្ញាណជាព្រះបច្ចេកពុទ្ធមួយអង្គ ដូចព្រះបច្ចេកពុទ្ធ ជាគ្រូនោះដែរ មិនយូរប៉ុន្មានមាណពបច្ចេកពុទ្ធក៏ចូលបរិនិព្វានទៅទាំងវ័យក្មេង គួរអោយសោកស្តាយសំរាប់បុគ្គលជាបុថុជ្ជន ។ អ្នកស្រុកភូមិនៅក្បែរនោះក៏នាំគ្នាធ្វើបុណ្យបូជាសព ហើយកសាងចេតិយមួយបញ្ចុះអដ្ឋិធាតុព្រះបច្ចេកពុទ្ធនោះត្រង់ផ្លូវបំបែក ។

បុរសជាឪពុកបាត់កូនយូរពេកក៏ទៅតាមរកកូនដល់ស្រុកនោះហើយសួររក ។ អ្នកស្រុកក៏បានប្រាប់តាមដំនើររឿងថា : កូនរបស់អ្នកឯងបានសំរេច ជាព្រះបច្ចេកពុទ្ធមួយអង្គចូលបរិនិព្វានបាត់ទៅហើយ ។ បុរសជាឪពុកក៏យំសោកអាល័យកូនបន្ទាប់មកក៏ទៅដងទឹកមកស្រោចស្រពទ្រនាប់ខ្សាច់ចេតិយ រួចយកក្រមាបង់មកចងធ្វើជាទង់ដោយឧទ្ទិសថ្វាយនៅមុខចេតិយហើយថ្វាយបង្គំលាវិលត្រលប់ទៅស្រុកវិញ ។ ឃើញដូច្នេះអ្នកស្រុកនៅជិតនោះក៏យកតំរាប់តាម លុះចំនេរកាលតមកទៀតក៏ក្លាយទៅជាទំនៀមទំលាប់ គឺពេលដែលហែរខ្មោចអាចារ្យតែងលើទង់ព្រលឹងដើរមុខរហូតដល់ទីចាំផា ទើបយកទង់នោះទៅដាក់នៅទិសឥសាន ជាសញ្ញាឱ្យខ្មោចនោះដឹងថា ខ្លួនត្រូវចេញ

ដំណើរទៅតាមទិសឥសាន ដើម្បីទៅថ្វាយបង្គំព្រះចុឡាមណី ចេតិយ ។

## ប្រវត្តិឆក់ក្រពើ ( ទី១ )

កាលព្រះសម្មាសម្ពុទ្ធ គង់ធរមាននៅឡើយ មានសត្វក្រពើញីឈ្មោល មួយគូមានសេចក្តីជ្រះថ្លា និងព្រះពុទ្ធសាសនាក៏ចូលទៅសុំព្រះពុទ្ធអង្គបួស តែព្រះពុទ្ធអង្គពុំព្រមអនុញ្ញាតព្រោះជាសត្វតិរច្ឆាន ។

ក្រពើនោះក្រាបទូលព្រះអង្គថា យើងខ្ញុំព្រះអង្គទាំងពីររូបនេះពុំមាននិស្ស័យក្នុងសាសនាព្រះអង្គទេ តែដោយយើងខ្ញុំទាំងពីរនេះ ស្រលាញ់ប្តូរផ្តាច់នូវសាសនាព្រះអង្គ យើងខ្ញុំព្រះអង្គធ្វើសំនូមពរថា " បើយើងខ្ញុំស្លាប់ទៅ សូមអោយគេយកស្បែកយើងខ្ញុំទៅដោតធ្វើជាទង់ថ្វាយចំពោះព្រះភ័ក្រ្តព្រះអង្គទុកជាសក្ការៈបូជាកុំបីខានឡើយ "។ ព្រះពុទ្ធអង្គទ្រង់ទទួលសំណូមពរនោះដោយព្រះមេត្តា ។ លុះក្រពើនោះស្លាប់ទៅ គេក៏យកស្បែកក្រពើទៅដោតថ្វាយតាមសំនូមពរមែន ។

លុះព្រះសម្មាសម្ពុទទ្រង់ចូលនិព្វានទៅស្បែកក្រពើនោះក៏ពុករលួយអស់ គេក៏នាំគ្នាយកសំពត់សរីក្រជាស មករចនាធ្វើ

ជារាងស្បែកក្រពើ ដើម្បីជាតំណាងតទៅទៀត ។ ដូចយើងតែង ឃើញគេដោតទង់ក្រពើនៅគ្រប់កន្លែងអាសនៈព្រះពុទ្ធរូបស្រាប់

## ប្រវត្តិទង់ក្រពើ ( ទី២ )

កាលណាមានមនុស្សស្លាប់ គេតែងយកទង់ក្រពើទៅចង នៅពីមុខផ្ទះ រឺទីណាមួយដែលញាតិមិត្តបងប្អូនជិតឆ្ងាយអាច មើលឃើញបាន ។ គេចងទង់ក្រពើមួយ រឺពីរ មិនកំណត់ហើយ ជាទំនៀមទំលាប់របស់ខ្មែរយើងពេញទាំងប្រទេសទៅហើយ ។ នៅសម័យដើម រឺសម័យនេះក៏ដោយ បើគ្រួសារខ្មែរយើងខ្លះនៅ កាន់ទំនៀមទំលាប់កប់សាកសពប៉ុណ្ណេះ ប៉ុណ្ណោះឆ្នាំទើបលើក យកឆ្អឹងមកបូជាក៏គេតែងចងទង់ក្រពើនៅក្បែរផ្នូរខ្មោច រហូត ដល់ទង់នោះដាច់ដោយខ្លួនឯង ។ ជួនអីថ្ងៃខួបនៃសពនោះ ដែលទទួល មរណភាពគេក៏ចងទង់ថ្មីមួយទៀតក៏មាន ។ ការ និយមចងទង់ក្រពើនេះ មានប្រវត្តដូចតទៅនេះ :

ក្នុងរាជស្តេចអង្គច័ន្ទទី ២ ( រាជធានីនៅឧដុង្គមានជ័យ ) ស្តេចមានបុត្រីមួយព្រះអង្គ ប្រកបដោយរូបល្អ ព្រះនាមព្រះអង្គ ម្ចាស់ក្សត្រី **ក្រពុំឈូក** ប៉ុន្តែកាលទ្រង់ព្រះជន្មបាន ១៦វស្សា ក៏ ត្រូវក្រពើមួយដ៏ធំឈ្មោះ **អាធន់** ដែលក្លាយខ្លួនមកពីលោកនេន មួយអង្គឈ្មោះ **នេនធន់** បានចាប់លេបទាំងរស់ ។ ស្តេចបិតា

ទ្រង់ បានចាត់ការផ្សងកន្ទោងខៀវដេញតាមក្រពើ **នេនធន់** អស់ពេលជាច្រើនថ្ងៃ ។ លុះដល់ថ្ងៃទី ៧ ក៏ចាប់ក្រពើនេះបាន នៅខេត្តក្រចេះ ។ ដោយមាតា នៃក្សត្រីក្រពុំឈូក នេះនឹក ស្រលាញ់បុត្រីខ្លាំងពេកក៏អោយគេវះពោះក្រពើយកបុត្រចេញ មកភ្លាម អោយបានទាន់ចិត្ត ប៉ុន្តែក្សត្រីក្រពុំឈូកបាន សុគតបាត់ សង្ខារទៅហើយ ។

ស្ដេចបិតាបានអោយគេ សង់វិហារមួយត្រង់កន្លែងវះ ក្រពើ នេនធន់ នោះដោយអោយធ្វើសសរដល់ទៅមួយរយ ។ នៅពីមុខវិហារសសរមួយរយនោះ ស្ដេចអោយធ្វើចេតិយមួយ យ៉ាងធំ ដោយអោយចាប់យកស្ត្រីមានផ្ទៃពោះ ២០ នាក់ មក សំលាប់យកក្បាលកល់ធ្វើជាគ្រឹះចេតិយ ហើយអោយសាងរូប ក្សត្រីក្រពុំឈូក ឈរលើចេតិយ ហើយអោយគេយកស្បែកក្រពើ នេនធន់ ទៅពន្ធះដោតផ្ដាងទាំងអស់នៅក្បែរចេតិយនោះផង ។

តាមសេចក្ដីតំណាលរបស់អ្នកស្រុកថា កាលពីជំនាន់ ដើម គ្មានអ្នកណាហ៊ានដើរកាត់មុខចេតិយនោះទេ បើស្ត្រីផ្ទៃ ពោះដើរ កាត់មុខ និងត្រូវស្លាប់ភ្លាម ។

សេចក្ដីតំណាលខាងលើនេះនាំអោយយើងយល់ថា ទង់ ក្រពើនេះមានរឿងរ៉ាវ វីបុញហេតុពីពេលនោះមក ដូច្នេះបានជា គេហៅទង់នេះថា **ទង់ក្រពើ** ព្រោះដើមហេតុមក ពីស្ដេចអង្គ

ចំនួនទី ២ បានអោយគេវះស្បែកក្រពើ នេនធន់ យកមកចងមុខព្រះចេតិយព្រះអង្គម្ចាស់ក្សត្រី ក្រពុំឈូក ជាបុត្រីនោះឯង ។

ទង់ក្រពើនេះ មានរូបរាងដូចស្បែកក្រពើ ដែលគេបានពន្លះចងផ្លាង មានក្បាលខ្លួន ជើងកន្ទុយ ប៉ុន្តែ ដោយហេតុថាសិល្បៈខ្មែរប្រភេទណាក៏ដោយ តែងមានការវិវត្តន៍ ប្រែប្រួលជានិច្ច ដូច្នេះបានជាទង់ក្រពើនេះជួនអីមានជើងដល់ទៅ ៨ មានកន្ទុយ ២ ។ ក្នុងពិធីបូជាសពលោកគ្រូចៅអធិការវត្ត រឺព្រះឧបជ្ឈាយ៍ រឺក៏លោកសង្ឃអង្គណាមួយ ដែលមានសមណស័ក្តិ គុណសម្បត្តិខ្ពង់ខ្ពស់ គេតែងធ្វើទង់ក្រពើនេះធំវែង មានក្បាច់ច្រើនហើយប្រើដោយកំណាត់សំពត់ច្រើនពណ៌ថែមទៀត។ ប៉ុន្តែតាមធម្មតា គេធ្វើតែត្រឹម ៥ ម៉ែតយ៉ាងវែង គេធ្វើដោយសំពត់សតែម្យ៉ាង ។ ទង់នេះគេច្រើនប្រើតែពីរប៉ុណ្ណោះ ប៉ុន្តែទង់តូចៗដែលដោតនៅជុំវិញឈាបនដ្ឋានជាដើម គ្មានកំណត់ថា ប៉ុន្មានៗឡើយ ។

## ប្រពៃណីដាក់ឆេងនិងមនុស្សស្លាប់ថ្មីៗ

កាលបើបុគ្គលស្លាប់ថ្មីៗ នៅលើផ្ទះអាចារ្យយោគី ត្រូវរកទឹកមួយក្អមតូច និងថ្មមួយដុំតូចហើយអុជធូប ៣ សរសៃយកទៅដាក់ ចុងជើងបុគ្គល រួចធ្វើឧបកិច្ចការពារកុំឱ្យអសុរកាយវា

ចូលក្នុងរូបបុគ្គលនោះបាន ។ បើមិនដូច្នេះទេ កាលណាមាន សត្វឆ្មា សម្បុរខ្មៅ លោតកន្លងបុគ្គលនោះ អសុរកាយ នឹងចូលក្នុងរូបបុគ្គលនោះបានពុំខាន ។ តែបើមិនបានធ្វើដូច្នេះទេត្រូវព័ទ្ធសីមា ។ បើបានព័ទ្ធសីមាហើយ ទោះបីមានឆ្មាខ្មៅលោតរំលងក៏មិនមានហេតុអ្វីដែរ ។

តាមជំនឿរបស់ខ្មែរថា អសុរកាយ ជាពួកបិសាចតែងត្រាច់រង្គត់រកស៊ីតំរង់ ហើយជួនកាលអាចបន្ទាចមនុស្សផងក៏មាន ទើបគេត្រូវតែ ការពារបុគ្គលដោយពិធីផ្សេងៗ ។ គេតែងប្រាប់គ្នា ឱ្យធ្វើកិច្ចផ្សេងៗ ចំពោះបុគ្គលស្លាប់ដូច្នេះ ដើម្បីចៀសវាងអន្តរាយដូចមានរឿងមួយ ដំណាលថា :

នៅស្រុកមួយឆ្ងាយពីទីប្រជុំជន ជាភូមិសំបូរដោយព្រៃស្ងាត់មានអាកាសធាតុត្រជាក់ ។ នៅតំបន់នោះមានផ្ទះមួយជាជំរកនៃមនុស្ស ៤ នាក់ គឺឪពុកម្ដាយ និងកូនប្រុស ២ នាក់ ដែលនៅក្នុងវ័យជំទង់ ។ ឪពុកចេញទៅរកស៊ីស្រុកឆ្ងាយយូរៗទើបវិលមកផ្ទះម្ដង ។ កូនប្រុស ២ នាក់ នៅជាមួយម្ដាយ ។ ថ្ងៃមួយជាថៃជន្ម អ្វីនាងម្ដាយនោះមានជំងឺជាទំងន់ក៏ធ្វើមរណកាលទៅ ។ ប្រជាជនដែលនៅភូមិជាមួយគ្នា ប៉ុន្តែផ្ទះគេនៅឆ្ងាយៗ នាំគ្នាមកជួយចាត់ចែងបុណ្យ ធ្វើក្ដារមឈូសដាក់សពរួចស្រេច ដល់ល្ងាចក៏ត្រលប់ទៅផ្ទះគេវិញអស់ទៅ ។ ផ្ទះសព

នោះ ក៏ត្រូវនៅត្រមោចកំព្រាមានតែកូន ២ នាក់ អុជភ្លើងបំប្លង់នៅចាំសពម្ដាយរង់ចាំដល់ភ្លឺ នឹងបានអ្នកជិតខាងមកជួយទៀត។ ឯសពនៅក្នុងក្ដារ មឈូសនោះពុំទាន់បានព័ទ្ធសីមា វិធ្វើកិច្ចអ្វីមួយឡើយ ព្រោះពេលក៏ខើច និងទៅរកអាចារ្យណាមក ក៏ពុំទាន់ណាមួយផ្លូវកាត់ព្រៃ ហើយត្រូវនឹង ពេលព្រលប់ជាពេលដែល សត្វសហាវចេញរកស៊ីផង ។

ក្នុងរាត្រីនោះក្មេងទាំងពីរនាក់បងប្អូនចេះតែនាំគ្នាភ័យព្រួយ ព្រោះយប់កាន់តែស្ងាត់ទៅ សត្វខ្មែងស្រោក លលកខ្មោចក៏ចេះតែបញ្ចេញ សំរែកគួរឱ្យព្រឺក្បាល ។ ថ្លែងពីអសុរកាយដែលតែងត្រាច់រង្កាត់រកសាកសព សត្វព្រៃជាអាហារលុះមកប្រទះឃើញខ្មោចនៅក្នុងក្ដារមឈូស ដែលមិនទាន់មានសីមាការពារនៅឡើយ ក៏រំលៀកខ្លួនចូលទៅសិកក្នុងរូបសពនោះមួយរំពេច ។ ខ្មោចដែលនៅស្ងួកស្ងឹងប្រៀបបាននឹងដុំឈើនោះ ក៏ស្រាប់តែហាក់ដូចជាមានវិញ្ញាណឡើងវិញ ហើបំរះប្រវេចប្រវារកងើបចេញពីក្ដារមឈូស ។ កុមារបងប្អូនដេកនៅជិតក្ដារមឈូស ប្អូនមិនទាន់ ដឹងការអ្វីច្រើន ក៏ដេកលក់ទៅ នៅតែកុមារបងដែលចេះតែមានការព្រួយបារម្ភ ។ លុះលឺសូរខ្មោចនោះរើក្នុងក្ដារ មឈូសវាចេះតែលួចសំលឹងទៅរកក្ដារមឈូសមិនយូរប៉ុន្មានស្រាប់តែខ្មោចនោះអើតក្បាលចេញពីក្ដារមកក្រូក់

កុមារបងឃើញដូច្នោះភ័យណាស់ កន្ត្រាក់ដៃប្អូនអូសរត់ចុះពីលើផ្ទះ ។ ប្អូនក៏ស្ទុះទៅតាមទាំងសើងម៉ឺង ។ បងនិយាយបណ្ដើររត់បណ្ដើរ ប្រាប់ប្អូនកុំឱ្យងាកក្រោយឱ្យសោះ ។ ក្មេងទាំងពីរនាក់រត់ទៅមិន យូរប៉ុន្មានខ្មោចនោះក៏លោតចុះដេញតាមពីក្រោយទៅដែរ ។ ឃើញដូច្នោះក្មេងទាំងពីរខំរត់សំដៅវត្តព្រោះគិតឃើញថា មានតែវត្តទេ ដែលអាចជួយខ្លួនឱ្យផុតអំពីភ័យអន្តរាយនេះ ។

ឯអសុរកាយលុះតាមទៅដល់របងវត្ត ឃើញសីមា វាមិនហានចូលក៏ចេញពីរូបសាកសពនោះទៅ ។ ឯសាកសពនោះក៏រលំដួលដេកនៅច្រងាងក្នុងទីនោះឯង ។

លុះព្រឹកឡើងព្រះសង្ឃ និងអ្នកស្រុកដឹងរឿងហើយក៏ផ្អើលមកមើល ហើយនាំគ្នាលើកខ្មោចនោះទៅបូជាធ្វើកិច្ចរំងាប់ចង្រៃគ្រប់បែបយ៉ាងទៅតាមទំលាប់ ។

ដោយខ្មោចមានហេតុអាក្រក់ជាចៃដន្យ ដូចក្នុងរឿងដំណាលនេះឯងហើយ ទើបចាស់បុរាណបានបង្គាប់គ្នាឱ្យរៀបធ្វើកិច្ចផ្សេងៗ និងឱ្យព័ទ្ធសីមាជាការចាំបាច់ ដើម្បីការពារទុកជាមុន ។ របៀបនេះក៏បានជាប់ជាទំនៀមទំលាប់រហូតមក ។

# ប្រវត្តិដាក់ទងនឹងទំនៀមទំលាប់ដាក់ខ្មោច បែរក្បាលទៅទិសខាងលិច

..................

រឿងនេះគេប្រកាន់តៗគ្នាមកតាំងពីកាលព្រះឥសូរកោរ ជុកឱ្យព្រះពិឃ្នេស ជាបុត្រ ដូចមានដំណាលក្នុងសាសនាព្រាហ្មណ៍ថា ព្រះឥសូររៀបចំកោរជុក ព្រះពិឃ្នេស តែភ្លេចអញ្ជើញព្រះអង្គារ ។ ព្រះអង្គារខ្ញាល់ក៏បណ្ដាលឱ្យកាំបិតកោរទៅកាត់យកក្បាលព្រះពិឃ្នេសបោះចោលទៅក្នុងមហាសមុទ្រ។ ព្រះឥសូរក៏ប្រើព្រះវិស្សកម្មឱ្យចុះទៅរកក្បាលមនុស្ស វិតិរច្ឆានណាដែលដេកដាក់ក្បាលទៅទិសខាងលិច ។

ព្រះពិស្ណុការទៅរកឃើញតែដំរីដេកបែរក្បាលទៅទិសខាងលិច ក៏កាត់យកក្បាលដំរីមួយយកទៅថ្វាយព្រះឥសូរ ៗ ក៏តភ្ជាប់ឱ្យព្រះពិឃ្នេស ។ ទើបព្រះពិឃ្នេសមានក្បាលជាដំរី ។

ព្រោះហេតុនោះទើបមនុស្សបុរាណប្រកាន់ជឿថា ទិសខាងលិចជាទិសអពមង្គល ហើយកាលណាមានមនុស្សស្លាប់ទៅគេដាក់ឱ្យបែរក្បាលទៅទិសខាងលិច ហើយក៏ដាក់ជាប់ជាទំនៀមរហូតមក ។

✧✧✧✧✧

# ប្រវត្តិដាក់មាសនិងដំណៀម ដាក់ប្រាក់ដាក់ ក្នុងមាត់បុគ្គលស្លាប់

មានរឿងបុរាណដំណាលតៗគ្នាមកថា ៖ មានបុរសម្នាក់នៅជាមួយនឹងប្រពន្ធ តាំងពីក្មេងដល់ចាស់ខំរកស៊ីធ្វើការបានសល់មាសមួយបាទ តែគ្មានកូនសោះ ។ ប្ដីប្រពន្ធនេះ បានផ្ដាំគ្នាទៅវិញទៅមកថា "បើអ្នកណាស្លាប់មុន ត្រូវយកមាសនេះដាក់ក្នុងមាត់អ្នកនោះ" ។ ចំនេរតមកមិនយូរប៉ុន្មានប្ដីស្លាប់មុនទៅ ។ ប្រពន្ធក៏យកមាស នោះដាក់ក្នុងមាត់ខ្មោចប្ដី ហើយយកខ្មោចប្ដីទៅធ្វើបុណ្យបូជា ។ ខ្មោចត្រូវភ្លើងឆេះសុះអស់ ឯមាសវិញត្រូវភ្លើងរលាយនៅសល់តែ ៣ ស្លឹង ។

សម័យមួយព្រះមហាក្សត្រមួយព្រះអង្គមានលោភចិត្តគ្របសង្កត់ ក៏ចេញព្រះរាជអាជ្ញា ឱ្យរៃយកមាសក្នុងមួយផ្ទះចំនួនមួយបាទជាកំហិត ។

យាយជាប្រពន្ធរបស់ខ្មោចតានោះក៏យកមាស ៣ ស្លឹង ដែលគាត់រើសទុកនោះទៅថ្វាយព្រះមហាក្សត្រ ហើយក្រាបទូលថា "ក្រាបទូលព្រះករុណា ! មាសនេះពីដើមពេញមួយបាទ តែខ្ញុំម្ចាស់យកទៅបង់មាត់ឱ្យប្ដី តែប្ដីខ្ញុំម្ចាស់យកទៅពុំបាន ក៏ត្រូវភ្លើងឆេះខាតអស់ខ្លះទៅ នៅសល់តែប៉ុណ្ណេះ សូមព្រះ

ករុណាមេត្តាដល់សត្វទាល់ក្រផងចុះ ខ្ញុំម្ចាស់ទាល់មធ្យោបាយ នឹងទៅរកមាសឯណា ឱ្យគ្រប់ចំនួនថ្វាយព្រះអង្គពុំបានឡើយ"។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ក៏កើតធម្មសង្វេគស្លុតព្រះទ័យ ទើបទ្រង់ប្រកាសឱ្យលើកលែង រៃយកមាសអំពីបណ្ដារាស្ត្រទៅទៀត ។

អាស្រ័យរឿងនេះ ទើបបណ្ដាលរាស្ត្រទាំងអស់យល់ថា ប្រាក់ រឺមាស ដែលបង់ក្នុងមាត់ខ្មោច មានអានុភាពទៅលើទឹកចិត្តមនុស្សណាស់ សូម្បីព្រះមហាក្សត្រ ក៏ចុះចាញ់អានុភាពនោះដែរ ។ មួយទៀតអានុភាពប្រាក់ រឺមាសបង់មាត់ខ្មោចនេះ ជាវត្ថុស័ក្តសិទ្ធ អាចជួយរំដោះគ្រោះថ្នាក់ក្នុងពេលមានអាសន្នបាន ។ ហេតុដូច្នេះឯង ទើបគេនាំគ្នាធ្វើរបៀបនេះជារឿងរាបរហូតកើតទៅជាទំនៀមទំលាប់មក ។

ប៉ុន្តែអ្នកប្រាជ្ញពីបុរាណ ដែលឱ្យយកមាស រឺប្រាក់ដាក់ក្នុងមាត់ខ្មោច គឺដើម្បីជាប្រស្នា ឱ្យពិចារណាថា "សម្បត្តិទាំងអស់យើងអាចយកដាក់នឹងខ្លួន ទៅបានខ្លះតែក្នុងវេលាមានជីវិតកាលបើស្លាប់ហើយយើងមិនអាចយកទៅបានទេ" ។

រឿងនេះឯងបានជាប់ជាទំនៀមទំលាប់ដល់សព្វថ្ងៃ ។

# ប្រវត្តិដាក់ធងនឹងទំនៀមដាក់ផ្កា និង ទៀនធូបក្នុងដៃ បុគ្គលស្លាប់

មានរឿងដំណាលថា : មានភិក្ខុមួយរូបមានឈ្មោះមិនប្រាកដ ។ ញោមប្រុសបស់លោកជាព្រានព្រៃ សំឡាប់សត្វច្រើនណាស់តាំងពីក្មេងដល់ចាស់ ។ លុះវេលាជិតនឹងស្លាប់គាត់ភ្ញាក់ស្មារតីទៅឃើញសត្វដែលខ្លួនបានសំឡាប់ដោយអកុសលចិត្ត ក៏ស្រែកប្រាប់ឱ្យភិក្ខុជាកូនជួយ ។ ភិក្ខុជាកូនដឹងថា "ញោមមានបាបកម្មច្រើនបានជាភ្ញាក់ទៅឃើញតែសត្វធាតុដូច្នេះ" ទើបឱ្យមនុស្សរកផ្កា ទៀនធូប យកមកដាក់ក្នុងដៃញោមប្រុសរួចប្រាប់ថា "ចូរញោមខំសំឡឹងមើលផ្កា ទៀនធូប ជាគ្រឿងបូជាព្រះរតនត្រ័យនេះឱ្យជាប់" ។ ញោមប្រុសនៃភិក្ខុនោះ កើតសទ្ធាជ្រះថ្លាមានចិត្តជាកុសលក៏ធ្វើតាមពាក្យកូន ។ លុះដល់ស្លាប់ទៅគាត់ក៏បានទៅកើតនៅឋានសួគ៌ ។

ព្រោះហេតុនោះបានជាមនុស្សជាន់ក្រោយធ្វើតាមតៗគ្នាមកដោយប្រាថ្នាឱ្យអ្នកជំងឺយកគុណព្រះរតនត្រ័យជាទីពឹង ។

ដោយហេតុរឿងនេះហើយក៏ជាប់ជាទំនៀមទំលាប់រហូតមក ។

# ប្រវត្តិបាក់ធ្លនឹងលោកអភិធម្ម និងលោកមាតិកា នៅពេលជន្លៃសព

មានរឿងនិទានថា : ក្នុងអតីតសម័យព្រេងនាយមានព្រះរាជាមួយព្រះអង្គទ្រង់សោយរាជ្យនៅនគរណោងស្មោ "ស្យាមប្រទេស" ។ ព្រះរាជាអង្គនេះទ្រង់មានព្រះហឫទ័យជ្រះថ្លានឹងព្រះពុទ្ធសាសនាយ៉ាងក្រៃលែង តែងធ្វើបុណ្យឱ្យទានជាអចិន្ត្រៃយ៍ ហើយទ្រង់មានព្រះទ័យរាប់អានស្និទ្ធស្នាល នឹងព្រះសង្ឃដែលគង់នៅវត្តមួយក្បែរព្រះបរមរាជវាំងណាស់ ទ្រង់តែងផ្គត់ផ្គង់ ព្រះសង្ឃដោយខាទនីយាហាររាល់ថ្ងៃ ពុំដែលខានឡើយ ។

លុះកាលក្រោយមក ព្រះរាជាអង្គនេះទ្រង់ប្រឈួនយ៉ាងធ្ងន់ ។ ពេទ្យហ្មនានា ដែលអញ្ជើញមកព្យាបាលជំងឺព្រះអង្គ ក៏ពុំអាចរកថ្នាំណានឹងទ្រទ្រង់ ជីវិតព្រះអង្គបាន ទ្រង់ក៏សោយព្រះទីវង្គតទៅ ។

នាម៉ឺនសព្វមុខមន្ត្រីក៏ជំនុំគ្នានឹងរៀបចំជង្វៃព្រះសពនោះឱ្យសមតាមឋានៈព្រះអង្គ ។

និយាយអំពីភិក្ខុ ៥ អង្គ ដែលព្រះរាជាទ្រង់តែងតែប្រគេនទ្វេចង្ហាន់ជានិច្ចកាលនោះក៏ប្រជុំប្រឹក្សាគ្នាថា "ព្រះរាជា

អង្គនេះកាលទ្រង់គង់ព្រះជន្មាយុនៅឡើយ ព្រះអង្គតែងតែផ្គត់ផ្គង់រូបយើងទាំងប្រាំនេះខ្លាំងណាស់

ឥឡូវនេះព្រះអង្គចូលទិវង្គតហើយ តើយើងរាល់គ្នាត្រូវធ្វើកិច្ចដូចម្ដេច ដើម្បីជាសក្ខីភាព នៃការតបស្នងសងគុណព្រះអង្គ នៅពេលដង្ហែព្រះសពចេញទៅបទក្សិណទីក្រុង ដោយយើងទាំង ៥ រូបជាអ្នកធម៌ស្រាប់ គួរនិមន្តលោកចៅអធិការឱ្យគង់នៅមុខព្រះសព ហើយចំរើនធម៌ **អភិធម្មមាតិកា** ឯ ៤ រូបទៀតគួរនៅគង់អមព្រះសពហើយចំរើន **សុត្តន្តមាតិកា** ទៅចុះ " ។

គិតគ្នាស្រេចហើយ លុះដល់ថ្ងៃកំណត់ដង្ហែព្រះសព ព្រះសង្ឃទាំង ៤ អង្គ ក៏នាំគ្នាចូលទៅសុំពួកនាម៉ឺនចាត់ការបុណ្យ ដើម្បីឱ្យបានចូលទៅអង្គុយ ហែតាមសេចក្ដីប្រឹក្សាគ្នាមកនោះ ។ ពួកមន្ត្រីចាត់ការបុណ្យ ក៏យល់ព្រមតាមការសុំរបស់ព្រះសង្ឃទាំង ៥ អង្គ ។ ហើយភាវនាធម៌រហូតដល់កន្លែងបូជាព្រះសព ។

តាមរឿងដូចបានពោលមកខាងលើនេះ ទើបកម្មវិធីបុណ្យខ្មោចមានលោកអភិធម្ម ១ អង្គ និងលោកមាតិកា ៤ អង្គ ជាប់ជាតំណររហូតមក ។

ទំនៀមទំលាប់នេះ មិនមែនមានតាំងពីសម័យពុទ្ធកាលមកនេះ គឺទើបតែនឹងចាត់មានត្រឹមព្រះសពស្ដេចអង្គនោះមកហើយ ក៏ជាប់ជាប្រពៃណីរហូមកដល់សព្វថ្ងៃនេះ ។

## ប្រវត្តិធាក់ធងនឹងធៀនភាពនៅពេលមានមនុស្សស្លាប់

អតីតកាលមានបុរសម្នាក់ជាមនុស្សត្រឹមត្រូវល្អណាស់ បើទៅកាន់ទីជំនុំចំណោមឯណា គេតែងរាប់រក ទុកជាមនុស្សមានប្រាជ្ញាជាអ្នកដឹងខុសត្រូវ ។ អ្នកនៅភូមិផង របងជាមួយ បើមានការអ្វីធំដុំតែងអញ្ជើញបុរសនោះមកជាប្រធាន ដើម្បីសួរយោបល់ រឺដើម្បីឱ្យជួយអារកាត់រឿងជាប់ជំពាក់ស្មុគ្រស្មាញ ។

ថ្ងៃមួយក្នុងរដូវប្រាំង មាណពនោះ បបួលបុរសពីរនាក់ទៀត ដែលនៅផ្ទះក្បែរគ្នា ទៅរកឃ្មុំយកក្រមួន និងទឹកវាលក់ ដើម្បីបំពេញសេចក្ដីខ្វះខាតក្នុងគ្រួសារ ។ បុរសទាំងពីរនាក់នោះក៏ស្រុះស្រួលសុខចិត្តទៅជាមួយគ្នា តែបណ្ដាអ្នកទាំងពីរនោះអ្នកមួយជាមនុស្សចេះស្ដាប់បង្គាប់ ឯអ្នកមួយទៀតជាមនុស្សរបឹងរឹងរូស មិនសូវចេះស្ដាប់ មិនសូវចេះត្រងត្រាប់ពាក្យប្រៀនប្រដៅទេ ។

លុះដើរទៅដល់ព្រៃ ឃើញខ្ទមអ្នកតាមួយដែលពួកធ្វើរព្រៃតែងបូជា ដើម្បីសុំបើកព្រៃរួចទើបចូលទៅ ។ មកដល់ជិតកន្លែងអ្នកតានោះទើបអ្នកទាំង ៣ នាក់ នាំគ្នា ធ្វើជំរកឈប់សំរាកបន្តិចសិនយកកំលាំង និងដើរទៅមុខទៀត ។ ក្នុងថ្ងៃនោះគេរកបានឃ្មុំមួយសំបុកមានក្រមួន ១២ គំឡឹង ហើយក៏ត្រលប់មកជំរកវិញ នាំគ្នាដាំបាយដុតត្រីបរិភោគ ។ តែមុននឹងបរិភោគ

គេចាប់ចាយ និងត្រីខ្វះដាក់លើស្លឹកឈើថ្វាយអ្នកតាសុំសេចក្ដីសុខសប្បាយ និងសុំឱ្យទៅរកឃ្មុំបានប្រទះដូចសេចក្ដីប្រាថ្នា ។

ឯបុរសម្នាក់ដែលជាអ្នករឹងរូសនោះឃើញអ្នកពីរនាក់សែនអ្នកតាក៏ទឹកខ្លាញ់ក្នុងចិត្តតែមិនចេញស្ដី ។ លុះព្រឹកឡើងមុននឹងចេញទៅរកឃ្មុំទៀត គេនាំគ្នាដាំបាយស៊ីហើយ ចាប់បាយបេះត្រីដាក់ថ្វាយអ្នកតាដូចថ្ងៃមុនទៀត ។ បុរសរឹងរូសទើសចិត្តណាស់ទ្រាំអត់ពុំបានក៏និយាយគំរោះថា " មិនដឹងជាថ្វាយអី ក៏ថ្វាយម្ល៉េះទេ ! ម្ហូបអាហារតិចផង យកទៅដាក់ចោលទៀត តើដាក់ឱ្យអាណាស៊ី ! " ថាហើយក៏ងើបដើរទៅយកបាយ និងត្រីរុកបញ្ចុកមាត់អ្នកតា ហើយនិយាយបែបចង់បញ្ឈោះឱ្យអ្នកដែលដាក់ថ្វាយនោះផងថា "ហ៎ ! ស៊ីទៅអ្នកតា ! ពីមុនថាគេមិនដាក់ឱ្យដល់មាត់ ឥឡូវអញដាក់ដល់មាត់ហើយ ម្ដេចក៏មិនស៊ីទៅឃើញតែទុកចោលស្រមោចរោម ម្ដងនេះតែមិនស៊ីឱ្យអញឃើញផងទេ លើកក្រោយៗលែងឱ្យទៀតហើយ" ។ អ្នកពីរនាក់ទៀតឃើញបុរសនោះធ្វើមិនគប្បីក៏នៅស្ងៀម រួចបបួលគ្នាចេញដំណើរទៅ ។ ក្នុងថ្ងៃនោះគ្មានរកបានឃ្មុំមួយសំបុកសោះ ព្រោះបុរសរឹងរូសនោះរវល់តែចុកពោះរមួលខ្លួនដើរមិនរួចទាល់តែសែងរហូតមកដល់ជំរកវិញ ។ មកដល់ហើយនាំគ្នាធ្វើដូចម្ដេចក៏ជំងឺនោះមិនស្រាកស្រាន្តឡើយ ។ លុះដល់កំឡាំងកាន់តែតិច

ទៅ បុរសឈើនោះនិយាយនឹងសំឡាញ់ទាំងពីរថា "ចូរឯងចែកក្រមួនឱ្យគ្នាមួយភាគផង ព្រោះខ្ញុំក៏បានទៅរកជាមួយដែរ" ។

បុរសពីរនាក់ឆ្លើយថា "ឯងចង់បានក្រមួនយកមកធ្វើអ្វី បើឯងជិតស្លាប់ទៅហើយយ៉ាងនេះ" ។ បុរសឈើនោះឆ្លើយវិញថា "ខ្ញុំយកទៅបានឱ្យតែឯងចែកមកឆាប់ឡើង បើឯងមិនឱ្យខ្ញុំទេ តើខ្ញុំបានអ្វីបំភ្លឺផ្លូវចេញពីព្រៃនេះរួច" ។

លឺដូច្នោះបុរសសំឡាញ់ពីរនាក់ ក៏នាំគ្នាថ្លឹងក្រមួនចែកជាបីភាគស្មើគ្នា ហើយយកស្លឹកឬស្សីងាប់ប្រវែងបង្គុយលលក (១) មកធ្វើជាប្រឆេះ ហើយយកក្រមួនមួយចំនែកទំងន់ប្រហែលជា ៤ តំលឹងមកលៃជា ៤ ភាគ យក ៣ ភាគលញ់ធ្វើទៀនគោល ។ ក្រមួននៅសល់មួយភាគទៀត គេយកស្លឹកត្រែងស្ងួត មកធ្វើជាប្រឆេះលញ់ទៀនរាយបួនទៀត ហើយកាប់មែកឈើដាក់គងលើមាត់ត្រឡោកទឹក ដែលយកទៅតាមខ្លួន យកទៀនធំបិទនឹងឈើនោះ ដើម្បីកុំឱ្យស្រក់ក្រមួនចោលទៅដី ហើយយកទៀនរាយបួនទៀតបិទនៅមាត់ត្រឡោក ។ លុះអុជទៀនរួចក៏អោននិយាយដាក់ ។

ក្រចៀកបុរសដែលឈឺនោះថា " នែសំឡាញ់ ចំណែកក្រមួនរបស់ឯង យើងធ្វើជាទានអុជឱ្យឯង ចូរឯងទទួលយកទៅ

---

១. កំពស់ដៃមនុស្សក្តាប់ ហើយលើកមេដៃឱ្យឈរឡើងលើ ។

តាមខ្លួនគ្រាន់ជាបំភ្លឺផ្លូវចេញពីព្រៃនេះទៅចុះ " បុរសឈើទទួលថា " អឺ ! " ហើយក៏ដាច់ខ្យល់ស្លាប់ទៅ ។

បុរសជាមិត្តក៏នាំគ្នាយកអុសភ្លើងមកដុតខ្មោចនោះ ហើយនាំគ្នាវេចខ្ចប់ធាតុយកមកឱ្យប្រពន្ធដោយប្រាប់តាមដំនើរតាំងពីរឿងឈើ ដល់រឿងចែកក្រមួន ។ តែមកដល់ត្រង់នេះប្រពន្ធនៃសពមិនយល់ព្រមដោយអាងថា "ប្ដីខ្លួនស្លាប់ទៅហើយតើអាចយកក្រមួនទៅផងម្ដេចបាន ? " ។ បុរសសម្លាញ់ពីរនាក់ពន្យល់យ៉ាងដូចម្ដេចនាងនោះក៏នៅតែមិនព្រម ទទួចយកតែចំណែក ក្រមួនតាំងពីថ្ងៃ រហូតដល់យប់ ហើយចូលទៅដេករៀងខ្លួនទៅ ។

និយាយពីប្រពន្ធរបស់បុរសស្លាប់លុះដេកលក់ទៅក៏យល់សប្តិឃើញប្ដីគាន់ទៀនដើរចូលមក ។ នាងក៏ស្រែកទាំងអរផងថា : " អ្នកអើយគេមកប្រាប់ខ្ញុំ ថាអ្នកឯងស្លាប់ហើយថែមទាំងបានចែកក្រមួនទៅអ្នកផង ឥលូវមានស្លាប់ឯណា ? អ្នកមកវិញហើយតើ ! " ឯខ្មោចនោះឆ្លើយមកវិញថា " បងស្លាប់មែនហើយបងបានក្រមួនដែលគេចែកឱ្យនោះធ្វើជាទៀនអុជរកផ្លូវចេញមកផ្ទះ កុំអីមិនដឹងជាវង្វេងទៅឆ្ងាយឯណាទេ !" ។ ប្រពន្ធលឺដូច្នោះក៏ស្ទុះទៅប្រវ៉ាអោបប្ដីភ្ញាក់ទាំងខ្លួនឡើង ទើបដឹងច្បាស់ថាខ្លួនយល់សប្តិ ។ លុះព្រឹកឡើងក៏ទៅប្រាប់បុរសទាំងពីរ

តាម ដំណើរយល់សប្តិ ហើយក៏ឈប់ប្រកាន់ " ឈ្មោះទៀត ទៅ " ។

ដោយហេតុមានរឿងដូច្នេះហើយក៏ប្រកាន់ជឿថា " បើ មនុស្សណាជិតស្លាប់ គេត្រូវតែធ្វើទៀនកាល អុជឱ្យ ដើម្បីឱ្យ ខ្មោចនោះបានពន្លឺ សំរាប់បំភ្លឺផ្លូវទៅរកឋានសុខ " ។

( ចប់ដោយសង្ខេប )

៚ ៛ ៙

❄